ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាលកម្ពុជា

# សូចនាករតាមដានរួមគ្នា ឆ្នាំ២០២១-២០២៣


រៀបចំដោយ

គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា



ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ខែកក្កដា ឆ្នាំ២០២១

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាលកម្ពុជា

# សូចនាករតាមដានរួមគ្នា ឆ្នាំ២០២១-២០២៣

រៀបចំដោយ

គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ខែកក្កដា ឆ្នាំ២០២១

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៧៦ សសរ

# សេចក្ដីសម្រេច

## ស្ដីពី

## សូចនាករតាមដានរួមគ្នា ឆ្នាំ២០២១-២០២៣

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ៦០ អនក្រ.បក ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល លេខ ០៣ ស.ស.រ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៩ ស្ដីពីយុទ្ធសាស្ត្រស្ដីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០១៩-២០២៣
- បានឃើញសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល លេខ៦៨ ស.ស.រ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៩ ស្ដីពីការអនុវត្តយន្តការពិគ្រោះយោបល់ និងឧបករណ៍នៃយុទ្ធសាស្ត្រស្ដីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០១៩-២០២៣
- បានឃើញសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល លេខ១៥៦ ស.ស.រ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៩ ស្ដីពីសូចនាករតាមដានរួមគ្នា ឆ្នាំ២០១៩-២០២៣

- យោងតម្រូវការចាំបាច់ក្នុងការលើកកម្ពស់គណនេយ្យភាពទ្វេទិស និងស័ក្តិសិទ្ធិភាពក្នុងកិច្ចសហប្រតិបត្តិការ អភិវឌ្ឍន៍

## សម្រេច

**ប្រការ ១. –**

ត្រូវបានដាក់ឱ្យអនុវត្តនូវសូចនាករតាមដានរួមគ្នា ឆ្នាំ២០២១-២០២៣ ដូចមានចែងក្នុងតារាងភ្ជាប់នឹងសេចក្តីសម្រេចនេះ ដើម្បីលើកកម្ពស់គណនេយ្យភាពទ្វេទិសរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ និងស័ក្តិសិទ្ធិភាពក្នុងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ សម្រាប់គាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រចតុកោណ- ដំណាក់កាលទី៤, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ និងយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០១៩-២០២៣ ។

**ប្រការ ២. –**

ប្រគល់ភារកិច្ចជូនឯកឧត្តម **ឈឿង យ៉ាណារ៉ា** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីសម្របសម្រួល និងបូកសរុបវឌ្ឍនភាពនៃការអនុវត្តសូចនាករតាមដានរួមគ្នា ដោយសហការជាមួយបណ្តាក្រសួង និងស្ថាប័ននៃរាជរដ្ឋាភិបាល, ដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធដទៃទៀតដើម្បីបញ្ចូលទៅក្នុងរបាយការណ៍ស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ។

**ប្រការ ៣. –**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័នពាក់ព័ន្ធ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ប្រធានក្រុមការងារបច្ចេកទេសចម្រុះ ដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធដទៃទៀត ព្រមទាំងសាមីខ្លួន ត្រូវអនុវត្តតាមសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ព្រហស្បតិ៍ ៦កើត ខែ ទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល:</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៣ «ដើម្បីអនុវត្ត»
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

# សូចនាករតាមដានរួមគ្នា ឆ្នាំ២០២១-២០២៣

ស្ថិតក្នុងបរិការណ៍សុខសន្តិភាព, ស្ថិរភាពនយោបាយ, ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចដោយប្រយ័ត្នប្រយែង និងដើម្បីបន្តជំរុញការអភិវឌ្ឍកម្ពុជាប្រកបដោយចីរភាព និងបរិយាប័ន្ន, រាជរដ្ឋាភិបាលកម្ពុជាបានដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ ដែលជារបៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ច សម្រាប់នីតិកាលទី ៦ នៃរដ្ឋសភា ។ គោលដៅចម្បងនៃយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ ផ្អែកលើសសរស្តម្ភទាំងបួន រួមមាន **កំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព** ដើម្បីសម្រេចគោលដៅប្រកបដោយមហិច្ឆតាជាប្រទេសមានចំណូលខ្ពស់ នាឆ្នាំ២០៥០ ។

ដើម្បីគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤, សូចនាករតាមដានរួមគ្នាត្រូវបានប្រើប្រាស់សម្រាប់តម្រង់ទិសសកម្មភាពការងារ ដើម្បីលើកកម្ពស់លទ្ធផលក្នុងកិច្ចអភិវឌ្ឍន៍ និងគណនេយ្យភាពទ្វេទិស ។ ទន្ទឹមនឹងនេះ ក៏ជាក្របខណ្ឌសម្រាប់កំណត់គោលដៅរយៈពេលមធ្យម ស្របតាមអាទិភាពដែលមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ, គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា, កម្មវិធីកែទម្រង់, យុទ្ធសាស្ត្រតាមវិស័យ និងផែនការយុទ្ធសាស្ត្រថវិកា ។ តាមរយៈការពិភាក្សារវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ក្នុងក្រុមការងារបច្ចេកទេសចម្រុះ, សូចនាករតាមដានរួមគ្នាត្រូវបានរៀបចំដោយផ្អែកតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងគោលនយោបាយ ឬផែនការតាមវិស័យ និងក្របខណ្ឌលទ្ធផលរបស់វិស័យ ហើយផ្សារភ្ជាប់ជាមួយនឹងដំណើរការកម្មវិធីនីយកម្ម និងថវិកានីយកម្ម ។

សូចនាករតាមដានរួមគ្នានេះ បានតម្រឹមជាមួយនឹងវិស័យអាទិភាពនៃយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ ដែលជាអាទិភាពខ្ពស់បំផុតសម្រាប់ឆ្នាំ ២០២១-២០២៣ ដែលរាជរដ្ឋាភិបាលប្តេជ្ញាអនុវត្តដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍ ។ សូចនាករតាមដានរួមគ្នាក៏បានរំលេចអំពីបរិការណ៍នៃការវិវត្តនៃជំងឺកូវីដ-១៩ ក្នុងគោលបំណងធ្វើឱ្យមានសង្គតិភាពជាមួយនឹងផែនការស្តារឡើងវិញក្រោយវិបត្តិកូវីដ-១៩ របស់រាជរដ្ឋាភិបាល ។

| **លទ្ធផលចុងក្រោយ (២០១៩-២០២៣)** | **លទ្ធផលក្នុងឆ្នាំ (២០២១-២០២៣)** | **សូចនាករលទ្ធផលក្នុងឆ្នាំ (២០២១-២០២៣)** |
|---|---|---|
| **<u>ស្នូលនៃយុទ្ធសាស្ត្រចតុកោណ</u>** : **<u>ការបង្កើនល្បឿនកែទម្រង់អភិបាលកិច្ច</u>** – គោលដៅជាយុទ្ធសាស្ត្រនៃអភិបាលកិច្ច គឺការធ្វើទំនើបកម្មស្ថាប័នរដ្ឋ និងការអភិវឌ្ឍប្រកបដោយបរិយាប័ន្ន, សមធម៌ និងយុត្តិធម៌ តាមរយៈការអនុវត្តសិទ្ធិអំណាចរដ្ឋខាងផ្នែកនយោបាយ សេដ្ឋកិច្ច និងរដ្ឋបាលក្នុងការដឹកនាំ គ្រប់គ្រង និងចាត់ចែងកិច្ចការប្រទេសជាតិ ពិសេសការធានានិរន្តរភាពនៃតួនាទី និងដំណើរការរដ្ឋបាលសាធារណៈ (ទំ. ២៤) ។ ការបង្កើនល្បឿនកែទម្រង់អភិបាលកិច្ច រួមមាន ១). ការកែទម្រង់ និងលើកកម្ពស់សមត្ថភាពស្ថាប័ន; ២). ការពង្រឹងភាពស្អាតស្អំក្នុងរដ្ឋបាលសាធារណៈ; ៣). ការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តការងារ និង ៤). ការពង្រឹងអភិបាលកិច្ចវិស័យឯកជន (ទំ. ២៥) ។ | | |

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) |
|---|---|---|
| **ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**<br><br>បូរណភាពនៃការគោរពវិន័យថវិកា, ប្រសិទ្ធភាពនៃថវិកា ទាំងក្នុងផ្នែកវិភាជន៍ ទាំងក្នុងផ្នែកប្រតិបត្តិការ និងស័ក្តិសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ | ១. ភាពជឿទុកចិត្តនៃថវិកានៅរក្សាបានជាសារវន្ត | ១.១. ការអនុវត្តចំណូលថវិកាសរុប (ថ្នាក់ជាតិ- ថ្នាក់ក្រោមជាតិកម្រិតរដ្ឋបាលរាជធានី- ខេត្ត) សម្រេចបានក្នុងរង្វង់ +/-៥% ធៀបនឹងច្បាប់ថវិកា<br>១.២. កំណើនចំណូលចរន្តប្រចាំឆ្នាំកើនឡើងយ៉ាងតិច ០,៣ ពិន្ទុភាគរយនៃ ផ.ស.ស<br>១.៣. ការអនុវត្តចំណាយសម្រេចបានក្នុងរង្វង់ +/-៥% ធៀបនឹងច្បាប់ថវិកា<br>១.៤. ក្របខណ្ឌរួម ផែនទីបង្ហាញផ្លូវ និងផែនការសកម្មភាព សម្រាប់ដោះស្រាយចំណាយកកស្ទះត្រូវបានរៀបចំ និងអនុវត្ត<br>១.៥. យ៉ាងតិច ៩៥% នៃផែនការលទ្ធកម្មប្រចាំឆ្នាំត្រូវបានអនុម័តឱ្យបានមុនថ្ងៃទី៣១ ខែធ្នូ មុនឆ្នាំអនុវត្តថវិកា<br>១.៦. ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីលទ្ធកម្មសាធារណៈត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្តក្នុងឆ្នាំ២០២២<br>១.៧. ការបោះជំហានទៅបង្កើនកម្រិតទឹកប្រាក់សិទ្ធិសម្រេចកិច្ចលទ្ធកម្មសាធារណៈរបស់ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវបានអនុវត្តក្នុងជំហានទី២ |
| | ២. ក្របខណ្ឌគណនេយ្យភាពហិរញ្ញវត្ថុត្រូវបានរៀបចំ, អនុវត្ត និងពង្រឹង និងតម្លាភាពថវិកាត្រូវបានបង្កើន | ២.១. ចំណាត់ថ្នាក់មុខងារត្រូវកែលម្អ និងប្រើប្រាស់សម្រាប់ការរៀបចំផែនការថវិកា ការតាមដាន និងការរៀបចំរបាយការណ៍ (បន្ទាត់មូលដ្ឋាន÷ ពុំទាន់បានប្រើប្រាស់)<br>២.២. មុខងារថ្មីចំនួន ២ បន្ថែម (រៀបចំផែនការថវិកា និងលទ្ធកម្ម) ត្រូវបានដាក់ឱ្យអនុវត្តជាផ្លូវការនៅគ្រប់ក្រសួង- ស្ថាប័ន អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្តទាំង ២៥<br>២.៣. - រដ្ឋបាលរាជធានី-ខេត្តទាំង ២៥ ត្រូវបានដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ FMIS<br>- អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញត្រូវបានដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ FMIS |

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) |
|---|---|---|
| | | - ដាក់ឱ្យប្រើប្រាស់សាកល្បងប្រព័ន្ធ FMIS នៅគ្រឹះស្ថានសាធារណៈរដ្ឋបាលយ៉ាងតិច ចំនួន ១៥<br>២.៤. សន្ទានកម្មរវាងប្រព័ន្ធ FMIS ជាមួយ÷<br>- ប្រព័ន្ធគ្រប់គ្រងបៀវត្សមន្ត្រីរាជការស៊ីវិលរបស់ក្រសួងមុខងារសាធារណៈ<br>- ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុនៃក្រសួងអប់រំ យុវជន និងកីឡា<br>២.៥. របាយការណ៍ហិរញ្ញវត្ថុត្រូវបានទាញចេញពីប្រព័ន្ធ FMIS ហើយមានអនុលោមភាពខ្ពស់ស្របតាមស្តង់ដា IPSAS Cash Basis<br>២.៦. គ្រប់ក្រសួង ស្ថាប័ន និងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ ត្រូវបានប្រកាសឱ្យអនុវត្តនីតិវិធីអនុវត្តការងារថ្មីតាមប្រព័ន្ធ FMIS លើ÷<br>- ការធានាចំណាយ និងទូទាត់ចំណាយថវិកាផ្សេងទៀតក្រៅពីទូទាត់បៀវត្ស និងទូទាត់ត្រង់ ដែលមានហានិភ័យកម្រិតទី១ និងកម្រិតទី២<br>- នីតិវិធីធានាចំណាយ និងទូទាត់ចំណាយទាំងអស់ ដែលមានហានិភ័យកម្រិតទី៣<br>២.៧. សូចនាករបំណុលគន្លឹះទាំង ៥ ស្ថិតក្រោមពិតានដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ |
| | ៣. ការពង្រឹងការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ | ៣.១. - អង្គភាពថវិកាត្រូវបានអនុវត្តគ្រប់ក្រសួង-ស្ថាប័ន និងរដ្ឋបាលខេត្តចំនួន២៥<br>- ថវិកាកម្មវិធីត្រូវបានពង្រឹង និងកែលម្អនូវការអនុវត្តនៅគ្រប់ក្រសួង-ស្ថាប័ន<br>- អង្គភាពថវិកាត្រូវបានជំរុញដាក់ឱ្យអនុវត្តនៅគ្រប់ក្រសួង-ស្ថាប័ន |

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) |
|---|---|---|
| | | - រដ្ឋបាលរាជធានី-ខេត្តទាំង ២៥ អនុវត្តថវិកាកម្មវិធី<br>៣.២. ក្របខណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម (MTFF) ឆ្នាំ ២០២៣-២០២៥ ត្រូវបាន អនុម័តនៅក្នុងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅឆ្នាំ២០២២<br>៣.៣. ចំនួនអង្គភាពថវិកាត្រូវបានបង្កើនអនុលោមតាមគោលការណ៍ណែនាំរបស់ កសហវ<br>៣.៤. ប្រតិភូកម្មសិទ្ធិអំណាចនៃការធ្វើនិយ័តថវិកាជូនរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយរដ្ឋបាលខណ្ឌជាជំហ៊ានៗ ក្នុងការធ្វើនិយ័តក្នុងកម្រិតអនុគណនី និងកម្រិតគណនីនៃជំពូកតែមួយ (ក្នុងសកម្មភាពតែមួយ) ដោយសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាខណ្ឌដែលមានការយល់ព្រមពីអភិបាលនៃគណៈអភិបាលរាជធានី<br>៣.៥. ច្បាប់ស្ដីពីភាពជាដៃគូរវាងរដ្ឋនិងឯកជនត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តក្នុងឆ្នាំ២០២១<br>៣.៦. អនុក្រឹត្យស្ដីពីការអនុវត្តនីតិវិធីប្រតិបត្តិការរួមសម្រាប់រៀបចំ និងគ្រប់គ្រងគម្រោងការវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជនត្រូវបានដាក់ឱ្យអនុវត្ត |
| | ៤. ក្របខណ្ឌគណនេយ្យភាពសមិទ្ធកម្ម ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | ៤.១. ច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ថ្មី) ត្រូវបានអនុម័តក្នុងឆ្នាំ២០២២<br>៤.២. អនុក្រឹត្យលេខ៨១ និងអនុក្រឹត្យលេខ៨២ ត្រូវបានកែសម្រួល និងអនុម័តក្នុងឆ្នាំ២០២២<br>៤.៣. គោលការណ៍ណែនាំស្ដីពីការការពារថវិកាសមិទ្ធកម្ម (លទ្ធផលក្នុងឆ្នាំ) ត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត<br>៤.៤. កិច្ចព្រមព្រៀងលើលទ្ធផលក្នុងឆ្នាំរវាងកសហវ និងក្រសួង-ស្ថាប័ន ត្រូវបានចុះហត្ថលេខាសម្រាប់ថវិកាឆ្នាំ២០២៣<br>៤.៥. PI-9 លទ្ធភាពសាធារណជនទទួលបានព័ត៌មានហិរញ្ញវត្ថុ (Fiscal information) មានភាពប្រសើរជាងមុន (PEFA ឆ្នាំ២០២០ ទទួលពិន្ទុ D) |

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) |
|---|---|---|
| | ៥. សមត្ថភាពមន្ត្រីរាជការលើវិស័យហិរញ្ញវត្ថុសាធារណៈត្រូវបានពង្រឹង | ៥.១. លិខិតបទដ្ឋានគតិយុត្តិកំណត់គុណវុឌ្ឍិសិក្ខាកាមនៃកម្មវិធីកម្រិតវិញ្ញាបនបត្រ (Certificated Program) លើជំនាញសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជូនមន្ត្រីរាជការក្រសួង-ស្ថាប័នត្រូវបានអនុម័ត និងអនុវត្តសាកល្បងចំនួនយ៉ាងតិច ៥ កម្មវិធីបណ្ដុះបណ្ដាលក្នុង១ឆ្នាំ<br>៥.២. សេចក្ដីព្រាងផែនការសកម្មភាពរួមនៃកម្មវិធីកែទម្រង់៣ បូក១ ស្ដីពីចក្ខុវិស័យ និងយុទ្ធសាស្រ្តកម្មវិធីកែទម្រង់៣ បូក១ |
| **ការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ**<br><br>រដ្ឋបាលថ្នាក់ក្រោមជាតិផ្ដល់សេវាសាធារណៈ និងអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានបានកាន់តែល្អប្រសើរ សំដៅរួមចំណែកលើកកម្ពស់សុខុមាលភាព និងគុណភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន | ១. រដ្ឋបាលរាជធានី-ខេត្តត្រូវបានពិនិត្យឡើងវិញ ដើម្បីរៀបចំរចនាសម្ព័ន្ធ និងមុខងាររដ្ឋបាលជារដ្ឋបាលថ្នាក់តំបន់ និងរដ្ឋបាលមេត្រូប៉ូលីតែន | ១.១. សេចក្ដីព្រាងក្របខណ្ឌច្បាប់សម្រាប់ការរៀបចំរដ្ឋបាលថ្នាក់តំបន់ និងរដ្ឋបាលមេត្រូប៉ូលីតែនត្រូវបានរៀបចំ និងដាក់ឱ្យអនុម័ត |
| | ២. មុខងារជាកាតព្វកិច្ច និងមុខងារជាអាណត្តិទូទៅត្រូវបានផ្ទេរឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីអនុវត្តប្រកបដោយប្រសិទ្ធភាព | ២.១. មុខងារជាកាតព្វកិច្ចយ៉ាងតិច៣ ដែលមានស្តង់ដា និងសេចក្ដីណែនាំបច្ចេកទេសត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត<br>២.២. មុខងារជាអាណត្តិទូទៅយ៉ាងតិច៣ ត្រូវបានកំណត់ច្បាស់លាស់ ដោយក្របខណ្ឌច្បាប់ជាក់លាក់ និងដាក់ឱ្យអនុវត្ត |

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) |
|---|---|---|
| | ៣. ការងារគណនេយ្យភាពសង្គម ត្រូវបានពង្រីកការអនុវត្ត ទាំងវិសាលភាពនៃតំបន់គោលដៅ និងវិសាលភាពនៃសេវាតាមវិស័យដែលត្រូវគ្របដណ្តប់ | ៣.១. ឃុំ-សង្កាត់យ៉ាងតិច៩០% បានអនុវត្តគណនេយ្យភាពសង្គម<br>៣.២. សាលាបឋមសិក្សាយ៉ាងតិច៩០% បានអនុវត្តគណនេយ្យភាពសង្គម<br>៣.៣. មណ្ឌលសុខភាពយ៉ាងតិច៩៥% បានអនុវត្តគណនេយ្យភាពសង្គម<br>៣.៤. រដ្ឋបាលក្រុង-ស្រុក-ខណ្ឌយ៉ាងតិច១៥% បានអនុវត្តគណនេយ្យភាពសង្គម<br>៣.៥. យ៉ាងតិចសេវាកម្មចំនួន១ ក្នុងចំណោមសេវាកម្មដូចជា អនាម័យទឹកស្អាត អាហារូបត្ថម្ភ ធនធានធម្មជាតិ និងការគ្រប់គ្រងកាកសំណល់ត្រូវបានបន្ថែមថ្មីនៅក្នុងការអនុវត្តគណនេយ្យភាពសង្គម |
| **ការកែទម្រង់រដ្ឋបាលសាធារណៈ**<br><br>ការកែលម្អការផ្តល់សេវាសាធារណៈ និងប្រព័ន្ធគ្រប់គ្រងផ្នែកលើសមិទ្ធកម្ម ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តជាបណ្តើរៗ ក្នុងរដ្ឋបាលសាធារណៈជាពិសេសក្នុងវិស័យសំខាន់ៗ (អប់រំ និងសុខាភិបាល) | ១. កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០២០-២០៣០ ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត ដោយផ្អែកលើកំណែទម្រង់ជាដំណាក់កាល ដើម្បីធានាឱ្យបាននូវរដ្ឋបាលស្អាតស្អំ ឆ្លាតវៃ ខ្លាំង និងផ្តោតលើប្រជាជនស្នូល | ១.១. កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត ដោយរាជរដ្ឋាភិបាល នៅឆ្នាំ២០២១<br>១.២. ផែនការសកម្មភាពកំណែទម្រង់រដ្ឋបាលសាធារណៈរបស់ក្រសួង-ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត នៅឆ្នាំ២០២១<br>១.៣. របាយការណ៍តាមដានវឌ្ឍនភាពការងារកែទម្រង់ប្រចាំឆមាស ត្រូវបានរៀបចំ |

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) |
|---|---|---|
| | ២. ប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តសាកល្បងក្នុងវិស័យ និងសេវាសាធារណៈ សំខាន់ៗ ដែលបានកំណត់ | ២.១. សេចក្តីណែនាំស្តីពីប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម ត្រូវបានដាក់ឱ្យអនុវត្តដោយរាជរដ្ឋាភិបាល នៅឆ្នាំ២០២១<br>២.២. វិស័យ និងសេវាសាធារណៈសំខាន់ៗ ត្រូវបានកំណត់ និងដាក់ឱ្យអនុវត្តសាកល្បងនូវប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម នៅឆ្នាំ២០២១ |
| | ៣. សេចក្តីព្រាងច្បាប់ស្តីពីសេវាសាធារណៈ និងកម្មវិធីវាយតម្លៃនិងទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូត្រូវបានរៀបចំ អនុម័ត និងដាក់ឱ្យអនុវត្តដើម្បីលើកកម្ពស់គុណភាព គណនេយ្យភាព និងតម្លាភាពក្នុងការផ្តល់សេវាសាធារណៈ | ៣.១. ច្បាប់ស្តីពីការផ្តល់សេវាសាធារណៈ ត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រី នៅត្រីមាសទី៤ ឆ្នាំ២០២២<br>៣.២. សូចនាករសមិទ្ធកម្មគន្លឹះសម្រាប់វាយតម្លៃ និងទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ (បឋមសិក្សា និងអនុវិទ្យាល័យ)និងសុខាភិបាល (មណ្ឌលសុខភាព) ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត នៅក្នុងត្រីមាសទី២ ឆ្នាំ២០២១<br>៣.៣. ការវាយតម្លៃ និងទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងសុខាភិបាល ត្រូវអនុវត្ត នៅត្រីមាសទី៣ ឆ្នាំ២០២១<br>៣.៤. វិស័យ និងសេវាសាធារណៈសំខាន់ៗដទៃទៀតនឹងត្រូវបានផ្តល់ជំនួយបច្ចេកទេសគាំទ្រក្នុងការរៀបចំសូចនាករសមិទ្ធកម្មគន្លឹះក្នុងការវាយតម្លៃនិងទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈ<br>៣.៥ ឯកសារណែនាំស្តីពីការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការនៃការផ្តល់សេវាសាធារណៈ ត្រូវបានដាក់ឱ្យអនុវត្តនៅត្រីមាសទី១ ឆ្នាំ២០២២ |

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) |
|---|---|---|
| **ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌**<br><br>សេវាកម្មយុត្តិធម៌ និងសិទ្ធិទទួលបានយុត្តិធម៌ត្រូវបានកែលម្អ | ១. ច្បាប់ និងគោលនយោបាយពាក់ព័ន្ធវិស័យយុត្តិធម៌ ត្រូវបានធ្វើទំនើបកម្ម និងដាក់ឱ្យអនុវត្ត | ១.១. ការបង្កើនចំនួនចៅក្រម និងព្រះរាជអាជ្ញា (បន្ទាត់មូលដ្ឋាន ២០១៨: ៤៣៧ នាក់; ចំណុចដៅ: បង្កើន ១០% រៀងរាល់ឆ្នាំ)<br>១.២. ភាពចង្អៀតណែនក្នុងពន្ធនាគារត្រូវបានកាត់បន្ថយ (បន្ទាត់មូលដ្ឋាន ២០១៨: ២៦២% នៃអាត្រាអ្នកជាប់ពន្ធនាគារ; ចំណុចដៅ: ២០០%)<br>១.៣. បង្កើនថវិកាជំនួយផ្នែកច្បាប់ដល់ជនក្រីក្រ (បន្ទាត់មូលដ្ឋាន ២០១៩: ៣០០.០០០ ដុល្លារ; ចំណុចដៅ: បង្កើន ២៥% រៀងរាល់ឆ្នាំ)<br>១.៤. សេចក្តីព្រាងច្បាប់អាជ្ញាសាលា, សាការី និងក្រឡាបញ្ជី និងនីតិវិធីតាក់តែងសេចក្តីព្រាងច្បាប់ ឬស្នើច្បាប់, សេចក្តីព្រាងច្បាប់ការពារសាក្សី និងការពារអ្នករាយការណ៍ ត្រូវបានតាក់តែងតាមរយៈដំណើរការប្រកបដោយតម្លាភាព និងពិគ្រោះយោបល់ (បន្ទាត់មូលដ្ឋាន: 0; ចំណុចដៅ: ៤)<br>១.៥. វិសោធនកម្មក្រមព្រហ្មទណ្ឌ, ក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ប្រឆាំងអំពើពុករលួយដំណើរការដោយតម្លាភាព និងមានការពិគ្រោះយោបល់ (បន្ទាត់មូលដ្ឋាន: 0; ចំណុចដៅ: ២)<br>១.៦. វិសោធនកម្មច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ត្រូវបានអនុម័ត<br>១.៧. ជនដែលត្រូវឃុំខ្លួនបណ្តោះអាសន្នគិតជាសមាមាត្រនៃអ្នកជាប់ឃុំទាំងអស់ (បន្ទាត់មូលដ្ឋាន: ៦៥%; ចំណុចដៅ: ៤៥ %)<br>១.៨. អ្នកទោសដែលមានសាលក្រមស្ថាពរអាចអនុវត្តបានគិតជាសមាមាត្រនៃអ្នកជាប់ឃុំទាំងអស់ (បន្ទាត់មូលដ្ឋាន២០១៨: ២៩%; ចំណុចដៅ: ៤៩%)<br>១.៩. ចំនួនអ្នកត្រូវផ្តន្ទាទោសដែលសម្រេចមិនឃុំខ្លួន (បន្ទាត់មូលដ្ឋាន: 0; ចំណុចដៅ: ៥០)<br>១.១០. ចំនួនស្ត្រីដែលត្រូវបានផ្តន្ទាទោសដោយមិនឃុំខ្លួន (បន្ទាត់មូលដ្ឋាន: 0; ចំណុចដៅ: ៥) |

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) |
|---|---|---|
| | ២. ការរៀបចំអង្គការតុលាការ ត្រូវបានពង្រឹង | ២.១. គោលការណ៍ណែនាំស្តីពីការគ្រប់គ្រងសំណុំរឿង/ការចុះបញ្ជីសំណុំរឿង ត្រូវបានអនុម័ត (បន្ទាត់មូលដ្ឋាន: ៤; ចំណុចដៅ: ៥)<br>២.២. ការបង្កើតសាលាឧទ្ធរណ៍តំបន់ (បន្ទាត់មូលដ្ឋាន: ១; ចំណុចដៅ: ៣)<br>២.៣. ការបង្កើតសូចនាករវាយតម្លៃការបំពេញការងាររបស់តុលាការទាំងអស់ (បន្ទាត់មូលដ្ឋាន: 0; ចំណុចដៅ: ១)<br>២.៤. ការសិក្សាស្រាវជ្រាវពីសុចរិតភាពតុលាការបានអនុវត្ត (បន្ទាត់មូលដ្ឋាន: 0; ចំណុចដៅ:១) |
| | ៣. ការគ្រប់គ្រងសំណុំរឿង និងព័ត៌មានត្រូវបានកែលម្អ | ៣.១. សំណុំរឿងកកស្ទះនៅតាមសាលាដំបូង ត្រូវបានកាត់បន្ថយ (បន្ទាត់មូលដ្ឋាន: ៤២% សម្រាប់រឿងរដ្ឋប្បវេណី និង ៨៧% សម្រាប់រឿងព្រហ្មទណ្ឌ; ចំណុចដៅ: ៣៨% សម្រាប់រឿងរដ្ឋប្បវេណី និង ៧៨% សម្រាប់រឿងព្រហ្មទណ្ឌ)<br>៣.២. របាយការណ៍វាយតម្លៃពីការចុះបញ្ជីការតុលាការនៅតាមសាលាដំបូង ត្រូវបានបញ្ចប់ (បន្ទាត់មូលដ្ឋាន: 0; ចំណុចដៅ: ១)<br>៣.៣. ចំនួនសាលក្រមព្រហ្មទណ្ឌសម្រាំងបានបោះពុម្ព (បន្ទាត់មូលដ្ឋាន: 0; ចំណុចដៅ: ៥0)<br>៣.៤. ចំនួនសាលក្រមរដ្ឋប្បវេណីសម្រាំងបានបោះពុម្ព (បន្ទាត់មូលដ្ឋាន: 0; ចំណុចដៅ: ៥0) |

<table>
<tr><th>លទ្ធផលចុងក្រោយ<br>(២០១៩-២០២៣)</th><th>លទ្ធផលក្នុងឆ្នាំ<br>(២០២១-២០២៣)</th><th>សូចនាករលទ្ធផលក្នុងឆ្នាំ<br>(២០២១-២០២៣)</th></tr>
<tr><td rowspan="3">ការប្រយុទ្ធប្រឆាំងអំពើពុករលួយ*<br><br>- បង្កើនសុចរិតភាព អភិបាលកិច្ចល្អ ក្នុងវិស័យសាធារណៈ និងការអប់រំប្រឆាំងអំពើពុករលួយ<br>- ជំរុញធុរកិច្ចស្អាតស្អំក្នុងវិស័យឯកជន<br>- ពង្រឹង និងបង្កើនប្រសិទ្ធភាព សុចរិតភាពក្នុងលទ្ធកម្មសាធារណៈ<br>- ជំរុញការងារប្រឆាំងការសម្អាតប្រាក់ និងការរឹបអូសផលនៃបទល្មើស<br>- ជំរុញការអនុវត្តអនុសាសន៍ដាក់ចេញពីការត្រួតពិនិត្យអនុសញ្ញា UNCAC នៅកម្ពុជាទាំង ២ ជុំ<br>- ពង្រឹងកិច្ចសហការរវាងអង្គភាពប្រឆាំងអំពើពុករលួយ និងសង្គមស៊ីវិល និងស្ថាប័នរដ្ឋសភា និងព្រឹទ្ធសភា</td><td>១. សិស្ស និស្សិត បុគ្គលិកគ្រឹះស្ថានឯកជន ទទួលបានការបណ្ដុះបណ្ដាលស្ដីពីការប្រឆាំងអំពើពុករលួយ</td><td>១.១. កម្មវិធីអប់រំស្ដីពីការប្រឆាំងអំពើពុករលួយនៅតាមសាលាវិជ្ជាជីវៈ គ្រឹះស្ថានឧត្ដមសិក្សា បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងគ្រឹះស្ថានឯកជន<br>១.២. ចំនួនការអប់រំផ្សព្វផ្សាយអំពីការប្រឆាំងអំពើពុករលួយ</td></tr>
<tr><td>២. ពង្រឹងកិច្ចការសហការ កិច្ចពិភាក្សាពិគ្រោះយោបល់ និងការបង្កើតគំនិតផ្ដួចផ្ដើមថ្មីៗ សំដៅបង្កើនការចូលរួមប្រឆាំងអំពើពុករលួយពីវិស័យឯកជន</td><td>២.១. ចំនួន MOU និងចំណាត់ការសហប្រតិបត្តិការក្នុងទម្រង់ផ្សេងៗ<br>២.២. ចំនួនកិច្ចប្រជុំ-ពិគ្រោះយោបល់ដែលបានរៀបចំជាមួយវិស័យឯកជន<br>២.៣. ចំនួនក្រុមហ៊ុនដែលចូលរួមគាំទ្រ ពាក់ព័ន្ធការប្រឆាំងអំពើពុករលួយ</td></tr>
<tr><td>៣. ចូលរួមសង្កេតការណ៍លើការអនុវត្តការងារលទ្ធកម្មសាធារណៈ តាមអង្គភាពលទ្ធកម្ម</td><td>៣.១. ចំនួនគម្រោង និងស្ថាប័នអនុវត្តលទ្ធកម្មដែលបានចូលរួមសង្កេតការណ៍</td></tr>
</table>

*សូចនាករតាមដានត្រូវបានកំណត់ដោយអង្គភាពប្រឆាំងអំពើពុករលួយ សម្រាប់អនុវត្ត និងតាមដានវឌ្ឍនភាព

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) |
|---|---|---|
| | ៤. ពង្រីក និងពង្រឹងកិច្ចសហការជាមួយស្ថាប័នជាតិ និងអន្តរជាតិលើការងារប្រឆាំងការសម្អាតប្រាក់ តាមរកទ្រព្យពាក់ព័ន្ធនឹងបទល្មើស និងរឹបអូសមធ្យោបាយប្រព្រឹត្តបទល្មើស និងផលនៃបទល្មើស | ៤.១. ចំនួនកិច្ចសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធថ្នាក់ជាតិ ស្ថាប័នអន្តរជាតិលើការងារប្រឆាំងការសម្អាតប្រាក់ តាមរកទ្រព្យពាក់ព័ន្ធនឹងបទល្មើស និងរឹបអូសមធ្យោបាយប្រព្រឹត្តបទល្មើស និងផលនៃបទល្មើស |
| | ៥. ទទួលអនុវត្តអនុសាសន៍របស់ UNODC ដែលមានក្នុងរបាយការណ៍ស្តីពីការត្រួតពិនិត្យការអនុវត្ត UNCAC ជុំទី២ | ៥.១. ផែនការសកម្មភាពស្តីពីការអនុវត្តអនុសាសន៍ UNCAC |
| | ៦. កិច្ចសន្ទនា/ពិគ្រោះយោបល់លើការងារប្រឆាំងអំពើពុករលួយ និងដោះស្រាយបញ្ហាប្រឈម ដែលចាំបាច់ត្រូវរួមគ្នាដោះស្រាយ | ៦.១. ចំនួនកិច្ចសន្ទនា/ពិគ្រោះយោបល់លើការងារប្រឆាំងអំពើពុករលួយ |

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) |
|---|---|---|
| **ផែនការ និងការកាត់បន្ថយភាពក្រីក្រ**<br><br>គោលដៅអាទិភាពជាតិ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជាត្រូវសម្រេចបាន តាមរយៈការអនុម័តនិងអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ហើយការអនុវត្តនេះ ត្រូវបានវាយតម្លៃផ្អែកលើទិន្នន័យ និងស្ថិតិប្រកបដោយគុណភាព ដែលជាផ្នែកមួយនៃប្រសិទ្ធភាពប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ | ១. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ ត្រូវបានអនុវត្តពេញលេញ ជាមួយគ្នានឹងកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ការរៀបចំផែនការ និងយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃត្រូវបានពង្រឹង ហើយរបាយការណ៍ពាក់កណ្តាលអាណត្តិឆ្នាំ២០២១ នៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៩-២០២៣និងរបាយការណ៍ត្រួតពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្ត២០២២ នៃការសម្រេចបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជាត្រូវបានរៀបចំ និងអនុម័ត | ១.១. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ ត្រូវបានអនុវត្តពេញលេញតាមរយៈផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យ និងផែនការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិ<br>១.២. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០២៤-២០២៨ ត្រូវបានពិភាក្សា រៀបចំ និងឯកភាពនៅកម្រិតអន្តរក្រសួង<br>១.៣. កម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិលត្រូវបានរៀបចំតាមវដ្តនៃការរៀបចំ និងស្នើសុំការអនុម័តពីរាជរដ្ឋាភិបាល ហើយកម្មវិធីវិនិយោគសាធារណៈ ត្រូវបានប្រើប្រាស់ជាឯកសារយោង សម្រាប់ការរៀបចំថវិកាជាតិប្រចាំឆ្នាំ<br>១.៤. របាយការណ៍ពាក់កណ្តាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្ត ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ត្រូវបានរៀបចំបញ្ចប់ និងអនុម័តដោយរាជរដ្ឋាភិបាល<br>១.៥. គោលការណ៍ណែនាំស្តីពីការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ត្រូវបានរៀបចំ និងអនុម័ត<br>១.៦. ពង្រឹងសុខដុមនីយកម្មរវាងផែនការថវិកា និងហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ (តាមរយៈការផ្សារភ្ជាប់រវាងការរៀបចំផែនការ និងការរៀបចំថវិកា)<br>១.៧. ភស្តុតាងត្រូវបានបង្កើតឡើង ដើម្បីជូនដំណឹងដល់ការរៀបចំអន្តរាគមន៍កាត់បន្ថយភាពក្រីក្រ និងរបាយការណ៍វាស់វែងភាពក្រីក្រ រួមទាំងរបាយការណ៍ភាពក្រីក្រពហុវិជ្ជភាព និងភាពក្រីក្ររបស់កុមារ |

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) |
|---|---|---|
| | ២. ក្របខណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ត្រូវបានអនុវត្តតាមរយៈ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ និងផែនការអភិវឌ្ឍន៍នៅថ្នាក់ក្រោមជាតិ និងតាមដានត្រួតពិនិត្យ និងវាយតម្លៃវឌ្ឍនភាពនៃការសម្រេចបាន | ២.១ ពិនិត្យឡើងវិញនូវចំណុចដៅ និងសូចនាកររបស់គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា ដើម្បីឆ្លើយតបនឹងផលប៉ះពាល់នៃការរីករាលដាលជំងឺកូវីដ-១៩<br>២.២ របាយការណ៍ត្រួតពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្ត ឆ្នាំ២០២២ នៃការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ត្រូវបានរៀបចំ និងបង្ហាញនៅក្នុងវេទិកាកម្រិតខ្ពស់របស់អង្គការសហប្រជាជាតិ។<br>២.៣. វឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងការសម្រេចបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជានៅថ្នាក់ក្រោមជាតិ ត្រូវបានតាមដានត្រួតពិនិត្យ |
| | ៣. សកម្មភាពអាទិភាពប្រចាំឆ្នាំនៃយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍស្ថិតិ ឆ្នាំ២០១៩-២០២៣ ត្រូវបានអនុវត្ត | ៣.១ ការអនុវត្តជំរឿន អង្កេត និងការចងក្រង ស្ថិតិផ្សេងទៀត<br>៣.២ ការសម្របសម្រួលប្រព័ន្ធស្ថិតិជាតិ និងការកសាងសមត្ថភាពត្រូវបានពង្រឹង និងអនុវត្ត<br>៣.៣. ការប្រើប្រាស់ និងការទទួលបានទិន្នន័យតាមរយៈការធ្វើទំនើបកម្ម ICT ត្រូវបានអនុវត្ត |
| **ភាពជាដៃគូ និងសុខដុមនីយកម្ម**<br><br>ការកៀរគរ និងគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ ប្រកបដោយស័ក្តិសិទ្ធិភាព ដើម្បីសម្រេចគោលដៅអាទិភាព | ១. ការតម្រឹមហិរញ្ញប្បទានសហប្រតិបត្តិការជាមួយនឹងអាទិភាពជាតិ | ១.១. ហិរញ្ញប្បទានសហប្រតិបត្តិការ គាំទ្រផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ<br>- តម្រូវការហិរញ្ញប្បទានសហប្រតិបត្តិការសរុប សម្រាប់គាំទ្រផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (បន្ទាត់មូលដ្ឋាន ២០១៨: ១,៣៨ ពាន់លានដុល្លារ; ចំណុចដៅ ២០២៣: ១,៩៧ ពាន់លានដុល្លារ)<br>- ភាគរយនៃហិរញ្ញប្បទានសហប្រតិបត្តិការ គាំទ្រផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ប្រមាណ ៩០% នៃចំណុចដៅ ឆ្នាំ២០២៣ ឬ +/- ១០%)<br>១.២. ភាគរយនៃហិរញ្ញប្បទានសហប្រតិបត្តិការ ប្រើប្រាស់ក្របខណ្ឌលទ្ធផលជាតិ (បន្ទាត់មូលដ្ឋាន ២០១៨: ៦៤%; ចំណុចដៅ ២០២៣: ៨០%) |

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) |
|---|---|---|
| អភិវឌ្ឍន៍ជាតិ ដូចមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ, និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា | ២. ការអនុវត្តយន្តការពិគ្រោះយោបល់ និងឧបករណ៍ នៃយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ សម្រាប់លើកកម្ពស់ស័ក្តិសិទ្ធិភាព ក្នុងការសម្របសម្រួល និងកៀរគរហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ | ២.១. យន្តការពិគ្រោះយោបល់:<br>- កិច្ចពិគ្រោះយោបល់ទ្វេភាគី (បន្ទាត់មូលដ្ឋានៈ តាមវដ្តនៃកម្មវិធីសហប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍន៍នីមួយៗ; ចំណុចដៅៈ ៥ ដង ក្នុង ១ឆ្នាំ)<br>- កិច្ចពិគ្រោះយោបល់ពហុភាគីក្នុងក្របខណ្ឌនៃយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០១៩-២០២៣ [កម្រិតវិស័យ/ក្រុមការងារបច្ចេកទេសចម្រុះ/អង្គការមិនមែនរដ្ឋាភិបាល/កិច្ចពិគ្រោះយោបល់នៅថ្នាក់ក្រោមជាតិ] (ចំណុចដៅៈ ២ ដង សម្រាប់យន្តការនីមួយៗ)<br>២.២. ការបូកសរុបសូចនាករតាមដានរួមគ្នា ឆ្នាំ២០២១-២០២៣ និងរបាយការណ៍វឌ្ឍនភាព (ចំណុចដៅ១: សូចនាករតាមដានរួមគ្នា ឆ្នាំ២០២១-២០២៣ ត្រូវបានអនុម័តក្នុងឆ្នាំ២០២១; ចំណុចដៅ ២: របាយការណ៍វឌ្ឍនភាពស្តីពីការអនុវត្តសូចនាករតាមដានរួមគ្នា ត្រូវបានរៀបចំ នាឆ្នាំ២០២៤)<br>២.៣. ភាពជាដៃគូសកលស្តីពីស័ក្តិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍន៍ ឬការអង្កេតសកលទីក្រុងប៊ូសាន (ចំណុចដៅ: ការចូលរួមធ្វើអង្កេតភាពជាដៃគូសកលទីក្រុងប៊ូសានស្តីពីស័ក្តិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍន៍នៅកម្ពុជា) |
| | ៣. វឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ត្រូវបានពិនិត្យ និងតាមដាន ដើម្បីធានាបានលទ្ធផលក្នុងកិច្ចអភិវឌ្ឍន៍ | ៣.១. របាយការណ៍ប្រចាំឆ្នាំស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ និងការពិនិត្យវឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូ (ចំណុចដៅ: របាយការណ៍ប្រចាំឆ្នាំស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ) |

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) |
|---|---|---|
| **<u>ចតុកោណទី ១</u> : <u>ការអភិវឌ្ឍធនធានមនុស្ស</u>**- ការអភិវឌ្ឍធនធានមនុស្ស ត្រូវបានចាត់ទុកជាអាទិភាពទី ១ នៃយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ៤, សំដៅលើកកម្ពស់ចំណេះដឹង, ជំនាញ, វិជ្ជាជីវៈ, សមត្ថភាពសហគ្រិនភាព, ការច្នៃប្រឌិត, នវានុវត្តន៍, គុណធម៌, សីលធម៌, មនសិការស្នេហាជាតិ និងស្មារតីទទួលខុសត្រូវ, សុខភាពល្អ និងកាយសម្បទារឹងមាំ, តួនាទីស្ត្រី និងកិច្ចគាំពារសង្គម ។ ក្នុងន័យនេះ ការអភិវឌ្ឍធនធានមនុស្សក្នុងនីតិកាលទី ៦ នឹងបន្តផ្តោតលើ ១). ការពង្រឹងគុណភាពវិស័យអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា; ២). ការបណ្តុះបណ្តាលជំនាញបច្ចេកទេស; ៣). ការលើកកម្ពស់សេវាសុខភាពសាធារណៈ និងអាហារូបត្ថម្ភ និង ៤). ការពង្រឹងសមភាពយេនឌ័រ និងការគាំពារសង្គម (ទំ. ៤២-៤៣) ។ | | |
| **វិស័យអប់រំ**<br><br>អត្រាបញ្ចប់ការសិក្សានៅកម្រិតអប់រំមូលដ្ឋានកើនឡើង ជាមួយនឹងលទ្ធផលនៃការសិក្សាប្រសើរឡើង | ១. អត្រាត្រួតថ្នាក់នៅបឋមសិក្សាថយចុះ ពិសេសនៅថ្នាក់ដំបូង | ១.១. អត្រាត្រួតថ្នាក់នៅបឋមសិក្សាថយចុះ (ចំណុចដៅ ២០២១/២០២២: ៤,៩% [ប្រុស ៥,៦% - ស្រី ៣,៤%] ផែនការយុទ្ធសាស្ត្រវិស័យអប់រំ) |
| | ២. លទ្ធផលសិក្សារបស់សិស្សនៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិកើនឡើង (ការសរសេរ និងគណិតវិទ្យានៅថ្នាក់ទី៦ និងថ្នាក់ទី៨) | ២.១. ភាគរយសិស្សសម្រេចបាន "លទ្ធផលសិក្សាក្រោមកម្រិតមូលដ្ឋាន" នៅថ្នាក់ទី៦:<br>- ការសរសេរ: បន្ទាត់មូលដ្ឋាន ២០១៧/១៨: ៣៩,៦%; ចំណុចដៅ ២០២០/២១: ៣៣.៦%<br>- គណិតវិទ្យា: បន្ទាត់មូលដ្ឋាន ២០១៥/១៦: ៥៣,២%; ចំណុចដៅ ២០២០/២១: ៤៧.២%<br>២.២. ភាគរយសិស្សសម្រេចបាន "លទ្ធផលសិក្សាក្រោមកម្រិតមូលដ្ឋាន" នៅថ្នាក់ទី៨:<br>- ការសរសេរ: បន្ទាត់មូលដ្ឋាន ២០១៧/១៨: ៧១%; ចំណុចដៅ ២០២១/២២: ៦៥%<br>- គណិតវិទ្យា: បន្ទាត់មូលដ្ឋាន ២០១៧/១៨: ៣៦,៣%; ចំណុចដៅ ២០២១/២២: ៣០,៣% |

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) |
|---|---|---|
| | ៣. អត្រានៃការសិក្សាកើនឡើង និង អត្រាបោះបង់ការសិក្សាថយចុះនៅមធ្យមសិក្សាបឋមភូមិ | ៣.១. អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិកើនឡើង (ចំណុចដៅ ២០២២/២៣: ៦៦,៧% [ប្រុស ៦៥% - ស្រី ៧២%])<br>៣.២. អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិថយចុះ (ចំណុចដៅ ២០២១/២២: ១០,៣% [ប្រុស ១០,៩% - ស្រី ៩,២%]) |
| **ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ**<br><br>បង្កើនលទ្ធភាពទទួលបានការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងពង្រឹងគុណភាពឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ | ១. ពង្រឹងគុណភាពនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឆ្លើយតបនឹងតម្រូវការទីផ្សារការងារ | ១.១. ភាគរយនៃសិក្ខាកាម សិស្ស និងនិស្សិតបានបញ្ចប់ការបណ្តុះបណ្តាល និងមានការងារធ្វើយ៉ាងតិច ៧០% (បន្ទាត់មូលដ្ឋាន ២០២០: ៧៣%; ចំណុចដៅឆ្នាំ២០២៣: ៧៥%)<br>១.២. ភាគរយនៃការពេញចិត្តរបស់និយោជក លើសិក្ខាកាម សិស្ស និងនិស្សិត ក្នុងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (បន្ទាត់មូលដ្ឋាន ២០២០: ៨២%; ចំណុចដៅឆ្នាំ២០២៣: ៨៥%)<br>១.៣. ចំនួនគ្រូបច្ចេកទេសទទួលបានការបណ្តុះបណ្តាល និងពង្រឹងសមត្ថភាព (បន្ទាត់មូលដ្ឋាន២០២០: ៥៧២នាក់ [ស្រី ៩៨នាក់]; ចំណុចដៅឆ្នាំ២០២១-២០២៣: ២.០០០នាក់ [ស្រីយ៉ាងតិច ៤០០នាក់]) |
| | ២. ពង្រីកការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដើម្បីគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម | ២.១. ចំនួនសិក្ខាកាមបានទទួលការបណ្តុះបណ្តាលវគ្គខ្លី -អត្រាស្រីយ៉ាងតិច ៥០% (បន្ទាត់មូលដ្ឋាន ២០២០: ៣៧.៣៣៣នាក់ [ស្រី ១៨.៣៣៤នាក់]; ចំណុចដៅឆ្នាំ ២០២១-២០២៣: ១១៧.០០០នាក់ [ស្រីយ៉ាងតិច ៥៨.៥០០នាក់])<br>២.២. ចំនួនសិក្ខាកាម សិស្ស និងនិស្សិតចុះឈ្មោះចូលរៀនវគ្គបណ្តុះបណ្តាលតាមក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជាកម្រិត១-៥កើនឡើងយ៉ាងតិចចំនួន ២០%-អត្រាស្រីយ៉ាងតិច ២៥% |

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) |
|---|---|---|
| | | (បន្ទាត់មូលដ្ឋាន ២០២០: ១២.១៩៣នាក់ [ស្រី ៣.៤៥១នាក់]; ចំណុចដៅឆ្នាំ២០២១-២០២៣: ៦២.០០០នាក់ [ស្រីយ៉ាងតិច ១៥.៥០០នាក់])<br>២.៣. ចំនួនអ្នកទទួលបានការធ្វើតេស្តវាយតម្លៃទទួលស្គាល់ការសិក្សាពីមុន និងសមត្ថភាពបច្ចុប្បន្ន (RPL/RCC) លើជំនាញអាទិភាព យ៉ាងតិចចំនួន ១០% ក្នុង១ឆ្នាំ - អត្រាស្រីយ៉ាងតិច ១០% (បន្ទាត់មូលដ្ឋាន២០២០: : ២.២៧៦នាក់ [ស្រី ៣០៥នាក់]; ចំណុចដៅឆ្នាំ២០២១-២០២៣: ៦.០០០នាក់ [ស្រីយ៉ាងតិច ៩០០នាក់]) |
| | ៣. ពង្រឹងភាពជាដៃគូរវាងរដ្ឋ និងឯកជន និងដៃគូនានាដើម្បីធានានិរន្តរភាពនៃការអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ | ៣.១. ចំនួនគ្រឹះស្ថានអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ បានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយសហគ្រាស-គ្រឹះស្ថាន (បន្ទាត់មូលដ្ឋាន២០២០: ៦៣ MOUs; ចំណុចដៅឆ្នាំ២០២១-២០២៣: ២០០ MOUs)<br>៣.២. ចំនួនសិស្ស-និស្សិតបានចុះកម្មសិក្សាតាមសហគ្រាស (បន្ទាត់មូលដ្ឋាន២០២០: : ៤.២៣៣នាក់ [ស្រី ៧៨៤នាក់]; ចំណុចដៅឆ្នាំ២០២១-២០២៣: ១៥.០០០នាក់ [ស្រីយ៉ាងតិច ៣.៧៥០នាក់])<br>៣.៣. ចំនួនសិស្សទទួលបានការបណ្ដុះបណ្ដាលក្នុងកម្មវិធីភាពជាដៃគូរវាងរដ្ឋនិងឯកជន (PPP) (បន្ទាត់មូលដ្ឋាន ២០២០: : ៥៧២នាក់ [ស្រី ៣២នាក់]; ចំណុចដៅឆ្នាំ២០២១-២០២៣: ១.៨០០នាក់ [ស្រីយ៉ាងតិច ៤៥០នាក់]) |

| **លទ្ធផលចុងក្រោយ (២០១៩-២០២៣)** | **លទ្ធផលក្នុងឆ្នាំ (២០២១-២០២៣)** | **សូចនាករលទ្ធផលក្នុងឆ្នាំ (២០២១-២០២៣)** |
|---|---|---|
| **វិស័យសុខាភិបាល**<br><br>ប្រព័ន្ធសុខាភិបាលជាតិដំណើរការល្អ និងធានានិរន្តរភាព បង្កើតបានលទ្ធផលល្អប្រសើរលើផ្នែកសុខភាព អាហារូបត្ថម្ភ និងសុខុមាលភាព សម្រាប់ប្រជាពលរដ្ឋកម្ពុជា ពិសេសជនក្រីក្រ, ជនងាយរងគ្រោះ, ស្ត្រី និងកុមារ | ១. ធ្វើឱ្យប្រសើរឡើងនូវសុខភាពបន្តពូជ សុខភាពមាតា, កុមារ និងទារកតាមរយៈការពង្រឹងគុណភាព និងស័ក្តិសិទ្ធិភាពនៃសេវាថែទាំសុខភាព | ១.១. សមាមាត្រនៃការសម្រាលនៅមូលដ្ឋានសុខាភិបាល ៩០% នាឆ្នាំ២០២០ នឹងរំពឹងថាកើនដល់:<br>- ៩១% ក្នុងឆ្នាំ២០២១<br>- ៩២% ក្នុងឆ្នាំ២០២២<br>- ៩៣% ក្នុងឆ្នាំ២០២៣<br>(យោងតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣) |
| **ជម្ងឺអេដស៍**<br><br>គោលដៅលុបបំបាត់ការរាលដាលនៃមេរោគអេដស៍ មិនឱ្យក្លាយជាការគម្រាមកំហែងសុខភាពសាធារណៈ ត្រឹមឆ្នាំ២០២៥ ដោយសម្រេចបានគោលដៅ ៩៥-៩៥-៩៥ | ១. សម្រេចឱ្យបានគោលដៅ ៩០-១០០-៩៨ | ១.១. ៩០% នៃអ្នកផ្ទុកមេរោគអេដស៍ទាំងអស់ដឹងពីស្ថានភាពរបស់ខ្លួន (បន្ទាត់មូលដ្ឋាន ២០១៩: ៨៤%)<br>១.២. ១០០% នៃអ្នកផ្ទុកមេរោគអេដស៍ទាំងអស់ដែលដឹងពីស្ថានភាពរបស់ខ្លួនទទួលបានការព្យាបាល (បន្ទាត់មូលដ្ឋាន ២០១៩: ១០០%)<br>១.៣. ៩៨% នៃអ្នកផ្ទុកមេរោគអេដស៍ទាំងអស់ដែលដឹងពីស្ថានភាពរបស់ខ្លួន ហើយទទួលបានការព្យាបាលមានបរិមាណមេរោគក្នុងឈាមទាបមិនអាចបង្កគ្រោះថ្នាក់ដល់អ្នកជំងឺ (បន្ទាត់មូលដ្ឋាន ២០១៩: ៩៦%) |
| | ២. អត្រាគ្របដណ្តប់ដោយកម្មវិធីគាំពារសង្គមលើអ្នករស់នៅជាមួយមេរោគអេដស៍ និងក្រុមប្រឈម | ២.១. ភាគរយនៃអ្នកផ្ទុកមេរោគអេដស៍ដែលទទួលបានការព្យាបាល បានចុះឈ្មោះក្នុងកម្មវិធីគាំពារសង្គម (បន្ទាត់មូលដ្ឋាននឹងត្រូវកំណត់នៅក្នុងឆ្នាំ២០២១) |

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) |
|---|---|---|
| | ៣. កំណើនថវិកាក្នុងស្រុកសម្រាប់ការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ | ៣.១. ៥០% នៃការចំណាយលើការងារអេដស៍បានមកពីថវិកាក្នុងស្រុក ត្រឹមឆ្នាំ២០២៣ (បន្ទាត់មូលដ្ឋាន ២០១៧: ២៤%) |
| **វិស័យគាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ**<br><br>ស្ថានភាពសន្តិសុខស្បៀង និងអាហារូបត្ថម្ភរបស់ប្រជាជនកម្ពុជាគ្រប់រូប ពិសេសជនក្រីក្រ, អសន្តិសុខស្បៀង និងជនងាយរងគ្រោះ ត្រូវបានលើកកម្ពស់ តាមរយៈប្រសិទ្ធភាព នៃការសម្របសម្រួល និងប្រព័ន្ធនៃការផ្តល់សេវាទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | ១. យុទ្ធសាស្ត្រ និងក្របខណ្ឌសម្រាប់បង្កើនប្រសិទ្ធភាព និងសកម្មភាពពហុវិស័យ ដើម្បីបញ្ចប់ភាពស្រេកឃ្លាន និងលុបបំបាត់បញ្ហាអាហារូបត្ថម្ភគ្រប់ទម្រង់ត្រឹមឆ្នាំ ២០៣០ ត្រូវបានសម្របសម្រួល និងធ្វើសុខដុមនីយកម្ម ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (រួមមានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ផែនការសកម្មភាពដើម្បីកាត់បន្ថយភាពស្រេកឃ្លានដល់កម្រិតសូន្យ, បណ្តាញចលនាបង្កើនអាហារូបត្ថម្ភ) | ១.១. យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ២០១៩-២០២៣ ត្រូវបានផ្សព្វផ្សាយ និងអនុវត្តទៅតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់៦ចំនុចរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី ដូចមានក្នុងសេចក្តីជូនដំណឹងរបស់រាជរដ្ឋាភិបាល លេខ៩៣៤ ហើយការពង្រឹងការអនុវត្តច្បាប់ត្រូវមានការគាំទ្រ (ឧទាហរណ៍ អនុក្រឹត្យលេខ ១៣៣ ស្តីពីការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារកនិងកុមារ ច្បាប់ការពារអ្នកប្រើប្រាស់ ការបញ្ចូលមីក្រូសារ-ជាតិទៅក្នុងចំណីអាហារ ស្តង់ដា សុវត្ថិភាពចំណីអាហារ)<br>១.២. របាយការណ៍វាយតម្លៃរួមប្រចាំឆ្នាំត្រូវបានរៀបចំ និងផ្ញើជូនលេខាធិការដ្ឋានចលនាបង្កើនអាហារូបត្ថម្ភពិភពលោក (របាយការណ៍ចំនួន៣ ត្រូវបានដាក់ជូនក្នុងកំឡុងឆ្នាំ២០២១-២០២៣)<br>១.៣. យន្តការ និងគោលការណ៍ណែនាំសម្រាប់ការងារពហុវិស័យ និងអន្តរស្ថាប័នត្រូវបានរៀបចំ ដើម្បីធ្វើការតស៊ូមតិ និងលើកកម្ពស់អាទិភាពតាមវិស័យ និងអាទិភាពរួមសម្រាប់សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ និងប្រធានបទដែលទាក់ទងទៅនឹង (ប្រព័ន្ធស្បៀង ការប្រែប្រួលអាកាសធាតុ គាំពារសង្គម បញ្ហាអន្តរវិស័យ និងជំងឺកូវីដ-១៩) |

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) |
|---|---|---|
| | ២. យន្តការសម្របសម្រួលវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវបានពង្រឹងដោយអនុវត្តតាមអភិក្រមភ្លោះនៅក្នុងយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភលើកទី២ ឆ្នាំ២០១៩-២០២៣ (តម្រឹមផែនការសកម្មភាព អាទិភាពតាមវិស័យ និងអាទិភាពរួម) | ២.១. យន្តការសម្របសម្រួលការងារតម្រឹមទឹកស្អាតនិងអនាម័យ និងអាហារូបត្ថម្ភ ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ត្រូវបានពង្រឹង<br>២.២. អនុក្រុមការងារសម្រាប់ផែនការអាទិភាពរួមទាំង៦ នៅក្នុងយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ លើកទី២ ឆ្នាំ២០១៩-២០២៣ ត្រូវបានបង្កើត និងអនុវត្តនៅថ្នាក់ជាតិ (រួមមានៈ អនុក្រុមការងាររបបអាហារសុខភាព, ខ្សែច្រវ៉ាក់តម្លៃស្បៀង សុវត្ថិភាពស្បៀង និងការបញ្ចូលមីក្រូសារជាតិទៅក្នុងចំណីអាហារ, អាហារូបត្ថម្ភដឹកនាំដោយសហ-គមន៍, ជំនួយសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ, សន្តិសុខស្បៀង និងអាហារូបត្ថម្ភក្នុងបរិបទគ្រប់គ្រងគ្រោះមហន្តរាយនិងការប្រែប្រួលអាកាសធាតុ)<br>២.៣. យុទ្ធសាស្ត្រសម្រាប់ពង្រីកក្រុមការងារដឹកនាំសម្របសម្រួលវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភខេត្ត (PWG-FSN) ត្រូវបានរៀបចំឡើង |
| | ៣. យន្តការគ្រប់គ្រងព័ត៌មាន និងចំណេះដឹង ដើម្បីប្រមូលភស្តុតាងលើកកម្ពស់ និងត្រួតពិនិត្យការងារសន្តិសុខស្បៀង និងអាហារូបត្ថម្ភត្រូវបានពង្រឹង | ៣.១. ពង្រឹង និងធ្វើសុខដុមនីយកម្មការគ្រប់គ្រងព័ត៌មាន និងចំណេះដឹងលើការងារអាទិភាពតាមវិស័យ និងអាទិភាពរួមក្នុងយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ (រួមមានរបបអាហារសុខភាព, ខ្សែច្រវ៉ាក់តម្លៃស្បៀង សុវត្ថិភាពស្បៀង និងការបញ្ចូលមីក្រូសារជាតិទៅក្នុងចំណីអាហារ, អាហារូបត្ថម្ភដឹកនាំដោយសហគមន៍, ជំនួយសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ, សន្តិសុខស្បៀងនិងអាហារូបត្ថម្ភក្នុងបរិបទគ្រប់គ្រងគ្រោះមហន្តរាយនិងការប្រែប្រួលអាកាសធាតុ)<br>៣.២. ពង្រឹងយន្តការត្រួតពិនិត្យ និងរបាយការណ៍ស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ |

| **លទ្ធផលចុងក្រោយ (២០១៩-២០២៣)** | **លទ្ធផលក្នុងឆ្នាំ (២០២១-២០២៣)** | **សូចនាករលទ្ធផលក្នុងឆ្នាំ (២០២១-២០២៣)** |
| --- | --- | --- |
| **សមភាពយេនឌ័រ**<br><br>យន្តការស្ថាប័ន និងដៃគូពាក់ព័ន្ធ បានពង្រឹងក្នុងការសម្របសម្រួលលើការងារពង្រឹងសមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី តាមរយៈក្របខណ្ឌគោលនយោបាយ និងកម្មវិធីជាតិក្នុងការបង្ការ និងឆ្លើយតបលើករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី, ភាពអង់អាចផ្នែកសេដ្ឋកិច្ច និងការចូលរួមរបស់ស្ត្រីក្នុងតួនាទីធ្វើសេចក្តីសម្រេច | ១. គោលនយោបាយជាតិស្តីពីសមភាពយេនឌ័រ បានអនុម័តដោយរាជរដ្ឋាភិបាល និងការរៀបចំប្រតិបត្តិការដែលមានសង្គតិភាពជាមួយការ ប្តេជ្ញាចិត្តជាតិ និងអន្តរជាតិសម្រាប់ការពង្រឹងសមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី | ១.១. សេចក្តីព្រាងគោលនយោបាយជាតិស្តីពីសមភាពយេនឌ័របានកែសម្រួលបញ្ចប់ដោយមានការពិគ្រោះយោបល់យ៉ាងទូលំទូលាយ និងទទួលបានការអនុម័តដោយរាជរដ្ឋាភិបាល (បន្ទាត់មូលដ្ឋាន: មិនទាន់មាន; ចំណុចដៅ ២០២១: ចំនួន១)<br>១.២. ប្រព័ន្ធតាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយជាតិស្តីពីសមភាពយេនឌ័រនៅតាមក្រសួង-ស្ថាប័ន និងតាមវិស័យត្រូវបានរៀបចំតាមរយៈយន្តការក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី និងចូលរួមអនុវត្តដោយក្រសួង-ស្ថាប័ននានា (បន្ទាត់មូលដ្ឋាន: 0; ចំណុចដៅ ២០២១: ១) |
| | ២. ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី លើកទី៣ ឆ្នាំ២០១៩-២០២៣ បានដាក់ឱ្យដំណើរការ ហើយការវាយតម្លៃលើការអនុវត្តច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ផ្តល់ធាតុចូលសម្រាប់កម្មវិធីកំណែទម្រង់ច្បាប់ដែលលើកកម្ពស់ការឆ្លើយតបនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី | ២.១. សេចក្តីព្រាងផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីលើកទី៣ បានពិគ្រោះយោបល់ និងអនុម័តដោយគណៈរដ្ឋមន្ត្រី ។ ផែនការសកម្មភាព និងថវិការបស់ក្រសួង-ស្ថាប័ន បានរៀបចំ និងចូលរួមឆ្លើយតបនឹងការអនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី (បន្ទាត់មូលដ្ឋាន: 0; ចំណុចដៅ: ២០២១-២០២៣)<br>២.២. ប្រព័ន្ធតាមដាននៃការអនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី, ផែនការសកម្មភាព និងថវិកាក្រសួង-ស្ថាប័ន បានរៀបចំ និងចែករំលែកនៅក្នុងកិច្ចប្រជុំរបស់ក្រុមការងារបច្ចេកទេសយេនឌ័រស្តីពីការទប់ស្កាត់អំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ (បន្ទាត់មូលដ្ឋាន: ២; ចំណុចដៅ ២០២១: ៣)<br>២.៣. ការប៉ាន់ប្រមាណលើការអនុវត្តច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ បានរៀបចំ និងចែករំលែករបកគំហើញនៃការប៉ាន់ប្រមាណដល់តួអង្គពាក់ព័ន្ធ (បន្ទាត់មូលដ្ឋាន: 0; ចំណុចដៅ ២០២១: ១) |

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) |
|---|---|---|
| | | ២.៤. ផែនទីចង្អុលផ្លូវ និងធាតុចូលសំខាន់ៗសម្រាប់កម្មវិធីកំណែទម្រង់ច្បាប់ បានឆ្លើយតបនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រីដោយប្រើប្រាស់របកគំហើញនៃការប៉ាន់ប្រមាណលើការអនុវត្តច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ (បន្ទាត់មូលដ្ឋាន: 0; ចំណុចដៅ ២០២១: ១) |
| | ៣. កម្មវិធីជាតិស្តីពីការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី និងយន្តការអភិក្រមតាមកម្មវិធីក្នុងការពង្រឹងសមភាពយេនឌ័រក្នុងតួនាទីធ្វើសេចក្តីសម្រេច បានអនុវត្តពេញលេញ | ៣.១. កម្មវិធីជាតិស្តីពីការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីបានតាក់តែង និងទទួលបានថវិការដ្ឋ និងធនធានពីដៃគូអភិវឌ្ឍន៍សម្រាប់អនុវត្ត (បន្ទាត់មូលដ្ឋាន: 0; ចំណុចដៅ ២០២១: ១)<br>៣.២. ក្រុមការងារបច្ចេកទេសយេនឌ័រស្តីពីស្ត្រីក្នុងភាពជាអ្នកដឹកនាំ និងអភិបាលកិច្ច បានដំណើរការមុខងារប្រកបដោយប្រសិទ្ធភាព ក្នុងការកៀរគរការគាំទ្រពីដៃគូពាក់ព័ន្ធ ដើម្បីឈានទៅសម្រេច និងតាមដានគោលដៅជាតិលើកកម្ពស់ការចូលរួមរបស់ស្ត្រី ក្នុងតួនាទីធ្វើសេចក្តីសម្រេច ដូចមានចែងក្នុងគោលដៅទី៥ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា (ចំណុចដៅ ២០១៩: កិច្ចប្រជុំប្រចាំត្រីមាស) |

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) |
|---|---|---|
| **ការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យនៅជនបទ**<br><br>ផែនការសកម្មភាពជាតិស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យនៅជនបទជំហាន ២ (NAP II)<br><br>ត្រឹមឆ្នាំ២០២៣ កំណើនប្រជាពលរដ្ឋនៅជនបទទទួលបាន និងប្រើប្រាស់នូវសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យប្រកបដោយសមធម៌ និងសុវត្ថិភាព<br><br>គោលដៅ NAP II:<br>- ៩០% មានលទ្ធភាពទទួលបានអនាម័យជនបទដែលមានការកែលម្អ<br>- ៩០% មានលទ្ធភាពទទួលបានសេវាផ្គត់ផ្គង់ទឹកស្អាតជនបទដែលមានការកែលម្អ | ១. សមត្ថភាពរបស់ក្រសួងអភិវឌ្ឍន៍ជនបទ, មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត, ក្រុមការងារទឹកស្អាត និងអនាម័យខេត្ត និងអាជ្ញាធរមូលដ្ឋាន ត្រូវបានពង្រឹងទាក់ទងទៅនឹងការរៀបចំផែនការ និងសម្របសម្រួល ដើម្បីកៀរគរឱ្យបង្កើនការវិភាជថវិកាបន្ថែម និងពិនិត្យតាមដានកម្មវិធី RWSSH រួមទាំងកម្មវិធីទឹកស្អាត និងអនាម័យនៅតាមស្ថាប័ន (សាលារៀន និងគ្រឹះស្ថានថែទាំសុខភាព) និងក្នុងពេលមានគ្រោះអាសន្ន | ១.១. ចំនួនក្រុមការងារទឹកស្អាត និងអនាម័យខេត្ត បានរៀបចំកិច្ចប្រជុំយ៉ាងតិចបីដង រួមទាំងកិច្ចប្រជុំប្រចាំឆ្នាំ ដើម្បីពិនិត្យតាមដានវឌ្ឍនភាពនៃ PAP II; កិច្ចប្រជុំយ៉ាងតិចមួយបានដាក់បញ្ចូលរបៀបវារៈអំពី WASH និងអាហារូបត្ថម្ភ (បន្ទាត់មូលដ្ឋាន: ៦; ចំណុចដៅ WASH MIS: ២៥)<br>១.២. ចំនួនខេត្តយ៉ាងតិច ៥០% នៃសូចនាករ PAP II ស្តីពីលទ្ធផលនៃការអនុវត្ត RWSSH ត្រូវបានប្រមូល និងកត់ត្រាទុកនៅក្នុង RWSSH MIS ថ្នាក់ជាតិ (បន្ទាត់មូលដ្ឋាន: ២៥; ចំណុចដៅ WASH MIS: ២៥)<br>១.៣. ចំនួនឃុំដែលបានវិភាជថវិកាសម្រាប់ការងារផ្គត់ផ្គង់ទឹកស្អាតក្នុងផែនការវិនិយោគឃុំ (បន្ទាត់មូលដ្ឋាន: ២១៩; ចំណុចដៅ WASH MIS: ១.៤០០)<br>១.៤. ចំនួនឃុំដែលបានវិភាជថវិកាសម្រាប់ការងារអនាម័យក្នុងផែនការវិនិយោគឃុំ (បន្ទាត់មូលដ្ឋាន: ៣០៨; ចំណុចដៅ WASH MIS: ១.៤០០) |
| | ២. ប្រជាជននៅជនបទ និងអ្នករស់នៅក្នុងតំបន់មានបរិស្ថានប្រឈម និងតំបន់ប៉ះពាល់ដោយសារធាតុអាសេនិក ទទួលបានសេវាផ្គត់ផ្គង់ទឹកផឹកដែលគ្រប់គ្រងដោយសុវត្ថិភាព | ២.១. ចំនួនប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតតាមទុយោដែលធន់នឹងអាកាសធាតុ ដែលគ្រប់គ្រងដោយសហគមន៍ អនុលោមតាមសៀវភៅណែនាំរចនាបច្ចេកទេស និងការត្រួតពិនិត្យការសាងសង់ (បន្ទាត់មូលដ្ឋាន: ៣២២; ចំណុចដៅ WASH MIS: ៧៧០)<br>២.២. ចំនួនឃុំដែលអនុវត្តផែនការសុវត្ថិភាពទឹក ដែលធន់នឹងអាកាសធាតុ ដោយផ្អែកលើគោលការណ៍ណែនាំជាតិសម្រាប់អនុវត្តផែនការសុវត្ថិភាពទឹកនៅជនបទ (បន្ទាត់មូលដ្ឋាន: ១១១; ចំណុចដៅ WASH MIS: ៥០០) |

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) |
|---|---|---|
| | ប្រកបដោយសមធមិ និងនិរន្តរភាពកើនឡើង | ២.៣. ចំនួនខេត្តដែលមានរបាយការណ៍ប្រចាំឆ្នាំអំពីការត្រួតពិនិត្យតាមដានគុណភាពទឹកផ្អែកលើគោលការណ៍ណែនាំជាតិសម្រាប់គុណភាពទឹកផឹក (បន្ទាត់មូលដ្ឋាន: ៦; ចំណុចដៅ WASH MIS: ២៥) |
| | ៣. ប្រជាជននៅជនបទ និងអ្នករស់នៅក្នុងតំបន់មានបរិស្ថានប្រឈមទទួលបានសេវាអនាម័យ ដែលគ្រប់គ្រងដោយសុវត្ថិភាព ប្រកបដោយសមធមិ និងនិរន្តរភាពកើនឡើង | ៣.១. ចំនួនឃុំបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាល (បន្ទាត់មូលដ្ឋាន: ១៨៧; ចំណុចដៅ WASH MIS: ៦០០)<br>៣.២. ចំនួនស្រុកបញ្ឈប់ការបន្ទោបង់ពាសវាលពាសកាល (បន្ទាត់មូលដ្ឋាន: ១៣; ចំណុចដៅ WASH MIS: ៣០)<br>៣.៣. ចំនួនខេត្តបញ្ឈប់បន្ទោបង់ពាសវាលពាសកាល (បន្ទាត់មូលដ្ឋាន: 0; ចំណុចដៅ WASH MIS: ០៤)<br>៣.៤. ចំនួនស្រុកដែលមានសហគ្រិនផ្គត់ផ្គង់ផលិតផល និងសេវាអនាម័យជាមូលដ្ឋាន (បន្ទាត់មូលដ្ឋាន: ១៨៥; ចំណុចដៅ WASH MIS: ២០៤) |
| | ៤. ប្រជាជននៅជនបទផ្លាស់ប្ដូរឥរិយាបទ និងប្រតិបត្តិអនាម័យល្អទាក់ទងទៅនឹងការផឹកទឹកសុវត្ថិភាព ការប្រើប្រាស់បង្គន់អនាម័យ និងការលាងដៃជាមួយនឹងសាប៊ូ | ៤.១. ចំនួនឃុំដែលលើកកម្ពស់ការគ្រប់គ្រងអនាម័យពេលមករដូវ (បន្ទាត់មូលដ្ឋាន: ៣១៣; ចំណុចដៅ WASH MIS: ៦០០) |

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) |
|---|---|---|
| **<u>ចតុកោណទី ២</u> : <u>ការធ្វើពិពិធកម្មសេដ្ឋកិច្ច</u>** - ការធ្វើពិពិធកម្មសេដ្ឋកិច្ចជាដំណើរការចាំបាច់ នៃការបង្កើតចន្ទល់ឱ្យបានច្រើនសម្រាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ច សំដៅពង្រីកការនាំចេញ ឬបង្កើតតម្លៃបន្ថែមពីសកម្មភាពសេដ្ឋកិច្ចដែលមានស្រាប់ ដើម្បីរក្សាកំណើនសេដ្ឋកិច្ចនៅក្នុងកម្រិតខ្ពស់ក្នុងរយៈពេលមធ្យម និងវែងខាងមុខ តាមរយៈការផ្តោតលើអាទិភាពចំនួន ៤ ដែលមានភាពប្រទាក់ក្រឡាគ្នាយ៉ាងជិតស្និទ្ធ និងបំពេញឱ្យគ្នាទៅវិញទៅមក គឺ ១) ការកែលម្អប្រព័ន្ធឡូជីស្ទីក, ការលើកកម្ពស់ការតភ្ជាប់ផ្នែកដឹកជញ្ជូន, ថាមពល និងឌីជីថល; ២) ការអភិវឌ្ឍប្រភពកំណើនសេដ្ឋកិច្ចគន្លឹះ និងថ្មីៗ; ៣) ការរៀបចំខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថល និងឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្មទី ៤ និង៤) ការជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងធនាគារ (ទំ. ៥៥) ។ | | |
| **ហេដ្ឋារចនាសម្ព័ន្ធ និង សមាហរណកម្មតំបន់**<br><br>ការកែលម្អប្រព័ន្ធឡូជីស្ទីក និងការលើកកម្ពស់ការតភ្ជាប់ផ្នែកដឹកជញ្ជូន, ថាមពល និងឌីជីថល | ១. ធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធឡូជីស្ទីក និងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ដោយធ្វើការលើកកម្រិតផ្លូវ និងពង្រីកទទឹងផ្លូវ ប្រកបដោយគុណភាព កែលម្អប្រព័ន្ធដឹកជញ្ជូនតាមផ្លូវដែក និងពង្រីកកំពង់ផែ | ១.១. បញ្ចូលផែនការមេថ្នាក់ជាតិស្តីពីការដឹកជញ្ជូន ជាមួយនឹងផែនការមេភស្តុភារកម្ម ក៏ដូចជាការផ្តួចផ្តើមការធ្វើឱ្យប្រសើរឡើងនូវមជ្ឈមណ្ឌលភស្តុភារកម្មរាជធានីភ្នំពេញ និងមជ្ឈមណ្ឌលភស្តុភារកម្មខេត្តព្រះសីហនុ ក្រោមគម្រោងអភិវឌ្ឍន៍ភាពជាដៃគូរវាងរដ្ឋ និងឯកជន (PPP):<br>- បញ្ចប់ផែនការមេពេញលេញស្តីពីប្រព័ន្ធដឹកជញ្ជូនពហុមធ្យោបាយ និងភស្តុភារកម្មសម្រាប់ប្រទេសកម្ពុជា ២០២១-២០២៣ ក្នុងឆ្នាំ២០២១ (បន្ទាត់មូលដ្ឋាន ២០២០: បានអនុម័តផែនការមេអន្តរកាល ស្តីពីការតភ្ជាប់ការដឹកជញ្ជូនពហុមធ្យោបាយ និងភស្តុភារកម្ម)<br>- ការចាប់ផ្តើមគម្រោងអភិវឌ្ឍមជ្ឈមណ្ឌលភស្តុភារកម្មរាជធានីភ្នំពេញ (PP-LC) (បន្ទាត់មូលដ្ឋាន ២០២០: បានបញ្ចប់ការចរចាលើកិច្ចព្រមព្រៀងក្របខណ្ឌ FA)<br>- ការចាប់ផ្តើមគម្រោងអភិវឌ្ឍន៍មជ្ឈមណ្ឌលភស្តុភារកម្មក្រុងព្រះសីហនុ (SH-LC) ក្រោមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន (បន្ទាត់មូលដ្ឋាន ២០២០: បានបញ្ចប់បុរេសិក្សាសមិទ្ធិលទ្ធភាព) |

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) |
|---|---|---|
| | | ១.២. ការស្តារ និងសាងសង់ផ្លូវជាតិ<br>- បន្តស្តារ និងសាងសង់ផ្លូវជាតិរួមមាន ផ្លូវជាតិលេខ៥ លេខ៤ លេខ៧១ C លេខ១០ លេខ៤៨ លេខ៣១ លេខ៣៣ លេខ៤១ លេខ៧ លេខ២៣ និងផ្លូវខេត្តលេខ ៣១២) ទិន្នន័យមូលដ្ឋានឆ្នាំ២០២០:<br>• ផ្លូវជាតិលេខ៥ ភាគខាងជើង (បាត់ដំបង- សិរីសោភ័ណ) ប្រវែង ៨៤.៧ គ.ម សម្រេចបាន៨៩,៧៥%<br>• ផ្លូវជាតិលេខ៥ ភាគកណ្តាល (ថ្លាម្អម-បាត់ដំបង) ប្រវែង ១១០,៩ គ.ម សម្រេចបាន ២៣,០២%<br>• ផ្លូវជាតិលេខ៥ ភាគខាងត្បូង (ព្រែកក្តាម- ថ្លាម្អម) ប្រវែង ១៣៥,២៥ គ.ម សម្រេចបាន ៣៥,៦២%<br>• ផ្លូវជាតិលេខ៥ ភាគកណ្តាល (សិរីសោភ័ណ- ប៉ោយប៉ែត) ប្រវែង ៣៥,៤ គ.ម (N/A)<br>• ផ្លូវជាតិលេខ៧១C (ត្បូងឃ្មុំ- ចំការលើ) ប្រវែង ១១៥ គ.ម ក្រាលកៅស៊ូបេតុង កំពុងដោះស្រាយផលប៉ះពាល់<br>• ផ្លូវជាតិលេខ១០ ប្រវែង ១៩៧ គ.ម ក្រាលកៅស៊ូបេតុង សម្រេចបាន ៤២.៤០%<br>• ផ្លូវជាតិលេខ៤៨ កំពុងជ្រើសរើសក្រុមហ៊ុនម៉ៅការសាងសង់<br>• ថែទាំផ្លូវជាតិលេខ៤ (ភ្នំពេញ- ព្រះសីហនុ) ប្រវែង ១៩៦,២០ គ.ម ក្រាលកៅស៊ូបេតុង កំពុងរៀបចំបើកកញ្ចប់ដេញថ្លៃ<br>• ផ្លូវជាតិលេខ៣១ ផ្លូវជាតិលេខ៣៣ ផ្លូវជាតិលេខ៤១ និងផ្លូវជាតិលេខ៧: (N/A)<br>- ប្រតិបត្តិការ នៃប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិផ្លូវថ្នល់គ្រប់គ្រងដោយ ក្រសួងសាធារណៈការ និងដឹកជញ្ជូន |

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) |
|---|---|---|
| | | - គាំទ្រដល់ការធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធត្រួតពិនិត្យគ្រោះថ្នាក់ចរាចរណ៍នៅក្នុងភាពជាដៃគូជាមួយគណៈកម្មការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក<br>- គម្រោងសាងសង់ផ្លូវល្បឿនលឿន (ភ្នំពេញ-ព្រះសីហនុ) គ្រោងបញ្ចប់ក្នុងឆ្នាំ ២០២២ (ឆ្នាំ២០២០ សម្រេចបាន ៣១,១៩%)<br>- បញ្ចប់ការចរចា និងរៀបចំកិច្ចព្រមព្រៀងសម្បទានសម្រាប់ការសាងសង់ផ្លូវល្បឿនលឿន (ភ្នំពេញ-បាវិត) បន្ទាត់មូលដ្ឋាន ២០២០: បានចុះកិច្ចព្រមព្រៀងក្របខណ្ឌ<br>១.៣. អភិវឌ្ឍចំណតកំពង់ផែកុងតឺន័រថ្មី និងប្រព័ន្ធផ្លាស់ប្ដូរទិន្នន័យកំពង់ផែ (Port EDI)<br>- ចាប់ផ្ដើមសាងសង់គម្រោងអភិវឌ្ឍន៍ចំណតកំពង់ផែកុងតឺន័រថ្មីក្រុងព្រះសីហនុ ដំណាក់កាលទី១ (ប្រវែង ៣៥០ ម៉ែត្រ និងជម្រៅទឹក ១៤,៥០ ម៉ែត្រ (បន្ទាត់មូលដ្ឋាន ២០២០ កំពុងបន្តរៀបចំប្លង់លម្អិត)<br>- ចាប់ផ្ដើមការងារសាងសង់គម្រោងពង្រីកចំណតកំពង់ផែកុងតឺន័រថ្មីក្រុងព្រះសីហនុ ដំណាក់កាលទី២ និងដំណាក់កាលទី៣ (បន្ទាត់មូលដ្ឋាន ២០២០: កំពុងបន្តសិក្សាសមិទ្ធិលទ្ធភាព)<br>- បញ្ចប់ការងារអភិវឌ្ឍន៍ Port EDI សម្រាប់ទំនើបកម្មបរិយាកាសកំពង់ផែ ក្នុងឆ្នាំ២០២៣ (បន្ទាត់មូលដ្ឋាន ២០២០: បានចុះហត្ថលេខាលើកិច្ចសន្យាក្រោមជំនួយឥតសំណង)<br>- ធ្វើឱ្យប្រសើរការគ្រប់គ្រង និងប្រតិបត្តិការច្រកកុងតឺន័រ (បន្ទាត់មូលដ្ឋាន ២០២០: កំពុងបន្តអនុវត្តជំនួយសហប្រតិបត្តិការបច្ចេកទេស (TCP) ដោយ JICA)<br>១.៤. ស្វែងរកដំណោះស្រាយកាត់បន្ថយការកកស្ទះចរាចរណ៍ក្នុងរាជធានីភ្នំពេញ និងក្រុងសៀមរាប |

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) |
|---|---|---|
| | | - បច្ចុប្បន្នភាពទិន្នន័យចរាចរណ៍រាជធានីភ្នំពេញ (បន្ទាត់មូលដ្ឋាន ២០២០: ទិន្នន័យចរាចរណ៍ធ្វើបច្ចុប្បន្នភាពចុងក្រោយក្នុងឆ្នាំ២០១២ ដោយ JICA)<br>- ធ្វើឱ្យប្រសើរឡើងនូវប្រតិបត្តិការសេវារថយន្តក្រុងក្នុងរាជធានីភ្នំពេញ (បន្ទាត់មូលដ្ឋាន ២០២០: កំពុងបន្តអនុវត្តជំនួយសហប្រតិបត្តិការបច្ចេកទេសដោយ JICA)<br>- ធ្វើឱ្យប្រសើរឡើងប្រព័ន្ធគ្រប់គ្រងចរាចរណ៍ក្នុងរាជធានីភ្នំពេញ (N/A)<br>- បន្តធ្វើការសិក្សាប្រព័ន្ធរថភ្លើងក្រោមដី (Subway) ក្នុងរាជធានីភ្នំពេញ (បន្ទាត់មូលដ្ឋាន ២០២០: បានបញ្ចប់ការសិក្សាគម្រោង AGT ដោយ JICA និងរថភ្លើងទំនើប Monorail ដោយ CCECC [ចិន])<br>- បង្កើតយុទ្ធសាស្ត្រ និងផែនការសកម្មភាព ដើម្បីរៀបចំជាទីក្រុងថ្មើរជើង និងចល័តភាពបៃតង សម្រាប់ខេត្តសៀមរាប (បន្ទាត់មូលដ្ឋាន ២០២០: ការសិក្សាគម្រោងរបស់ធនាគារពិភពលោកកំពុងដំណើរការ) |
| | ២. អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តជនបទ | ២.១. ផ្លូវជនបទប្រវែង ៣,៩៥៨ គ.ម ត្រូវបានស្ថាបនា និងតភ្ជាប់ជាបណ្តាញសំដៅលើកកម្ពស់វិស័យហេដ្ឋារចនាសម្ព័ន្ធ [ប្រវែងកំណាត់ផ្លូវ ៣,០៣៤ គ.ម គឺជាប្រវែងដែលមិនទាន់សម្រេចបាននៅក្នុងសូចនាករគោលដៅកាលពីឆ្នាំ២០១៩-២០២០ ហើយចំណែកប្រវែងផ្លូវ ៩២៤ គ.ម គឺជាប្រវែងបូកបន្ថែមថ្មី] (បន្ទាត់មូលដ្ឋាន ២០២០: ៩៩៥ គ.ម; ចំណុចដៅ: ១,១៩៦ គ.ម [២០២១]; ១,៣១៥ គ.ម [២០២២]; ១,៤៤៧ គ.ម [២០២៣]) |

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) |
| --- | --- | --- |
| | | ២.២. ផ្លូវជនបទប្រវែង ២,៩៩១ គ.ម ត្រូវបានកែលម្អទៅជាផ្លូវកៅស៊ូពីរជាន់ ឬបេតុង ដើម្បីឱ្យមានភាពធន់នឹងបញ្ហាបម្រែបម្រួលអាកាសធាតុ (បន្ទាត់មូលដ្ឋាន ២០២០: ៣៨២ គ.ម; ចំណុចដៅ: ៩០៤ គ.ម [២០២១]; ៩៩៤ គ.ម [២០២២]; ១,០៩៣ គ.ម [២០២៣] |
| | ៣. ពង្រឹងហេដ្ឋារចនាសម្ព័ន្ធឌីជីថលតាមរយៈសមាហរណកម្ម ប្រព័ន្ធខ្សែកាបអុបទិកក្រោមបាតសមុទ្របំពេញប្រតិបត្តិការ ប្រកបដោយប្រសិទ្ធភាព ស្ថិរភាពនិងងាយស្រួល ពង្រីកចំណុះល្បឿននៃការតភ្ជាប់បណ្ដាញទាន់ពេលវេលាដើម្បីត្រៀមជាស្រេចសម្រាប់ធុរកិច្ច និងប្រជាពលរដ្ឋចូលរួមក្នុងដំណើរការបរិវត្តកម្មឌីជីថល | ៣.១. ខ្សែកាបបាតសមុទ្រអុបទិកនិងហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធពីខេត្តព្រះសីហនុទៅហុងកុងត្រូវបានសាងសង់ (បន្ទាត់មូលដ្ឋាន២០២០: ការសិក្សាលទ្ធភាពត្រូវបានបញ្ចប់ហើយកិច្ចសន្យាសេវាកម្មត្រួតពិនិត្យត្រូវបានចុះហត្ថលេខា; ចំណុចដៅ២០២១-២០២៣: បញ្ចប់ប្រព័ន្ធខ្សែកាបក្រោមដី ប្រមាណ២៧១៥ គ.ម និងស្ថានីយកំណត់ខ្សែកាប)<br>៣.២. ប្រព័ន្ធខ្សែស្នូលភ្នំពេញ-ព្រះសីហនុតាមបណ្ដោយផ្លូវល្បឿនលឿនភ្នំពេញ-ព្រះសីហនុត្រូវបានសាងសង់ (បន្ទាត់មូលដ្ឋាន២០២០: N/A; ដំណុចដៅ២០២១-២០២៣: ដាក់ខ្សែកាបអុបទិកសរុប ២៣០ គ.ម និងដំឡើងឧបករណ៍បញ្ជូន)<br>៣.៣. មជ្ឈមណ្ឌលទិន្នន័យជាតិក្នុងរាជធានីភ្នំពេញត្រូវបានសាងសង់ឡើង (បន្ទាត់មូលដ្ឋាន ២០២០: N/A; ចំណុចដៅ២០២១-២០២៣: បញ្ចប់ការសាងសង់ និងមធ្យោបាយនានា)<br>៣.៤. ហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងការតភ្ជាប់អ៊ីនធឺណិត÷ គម្លាតហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗត្រូវបានកំណត់ ហើយលទ្ធកម្មបានជឿនលឿនសម្រាប់ការធ្វើឱ្យប្រសើរឡើងនូវបណ្ដាញអ៊ីនធឺណិតសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការកែលម្អហេដ្ឋារចនាសម្ព័ន្ធឌីជីថលរបស់រាជរដ្ឋាភិបាល (Cloud) |

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) |
|---|---|---|
| | ៤. បង្កើនសមត្ថភាពផ្គត់ផ្គង់ថាមពលអគ្គិសនីឱ្យកាន់តែមានស្ថិរភាព និងកាត់បន្ថយការបាត់បង់ | ៤.១. ធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធខ្សែបណ្ដាញជាតិបញ្ជូនថាមពល<br>បន្ទាត់មូលដ្ឋាន ២០២០: ៣១២៩.៨៣ គ.ម នៃប្រព័ន្ធបញ្ជូនបណ្ដាញដែលបានពង្រីក÷<br>- ៥០០ គ.វ : ១៧៩ គ.ម<br>- ២៣០ គ.វ : ១៨៨១.១៣ គ.ម<br>- ១១៥ គ.វ : ១០៦៩.៧០ គ.ម<br>ចំណុចដៅ ២០២៣: ៣៥៦៤.៨៣ គ.ម នៃប្រព័ន្ធបញ្ជូនបណ្ដាញដែលបានពង្រីក÷<br>- ៥០០ គ.វ : ២៥១គ.ម<br>- ២៣០ គ.វ : ១៩៨៩.១៣គ.ម<br>- ១១៥ គ.វ : ១២៩៤.៧០គ.ម<br>៤.២. ធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធខ្សែបណ្ដាញអគ្គិសនីភាវូបនីយកម្មជនបទ<br>បន្ទាត់មូលដ្ឋាន ២០២០:<br>- បានពង្រីកការចែកចាយបណ្ដាញប្រវែង ៣៧១៦១ គ.ម (វិនិយោគដោយ EDC ១៧.១៦៩ គ.ម និង ១៩.៩៩២ គ.ម ដោយ Licensee)<br>- បានពង្រីកការចែកចាយបណ្ដាញ ៤០៥៩២ គ.ម (វិនិយោគដោយ EDC ៨.៨២០ គ.ម និង ៣១.៧៧២ គ.ម ដោយ Licensee)<br>ចំណុចដៅ ២០២៣:<br>- បានពង្រីកការចែកចាយបណ្ដាញតង់ស្យុងមធ្យម (MV) ប្រវែង ៤០០៦១ គ.ម<br>- បណ្ដាញចែកចាយតង់ស្យុងទាប (LV) ត្រូវបានពង្រីក (កំណត់ចំណាំ÷ មិនអាចកំណត់ចំនួនគោលដៅបានច្បាស់) |

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) |
|---|---|---|
| **ចតុកោណទី ៣ : ការអភិវឌ្ឍវិស័យឯកជន** - ការអភិវឌ្ឍវិស័យឯកជននៅតែបន្តជាអាទិភាពរបស់រាជរដ្ឋាភិបាលក្នុងអភិក្រមអភិវឌ្ឍសេដ្ឋកិច្ចទីផ្សារ និងមានតួនាទីគន្លឹះក្នុងការជំរុញកំណើន និងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ។ ការអភិវឌ្ឍវិស័យឯកជននឹងត្រូវបានអនុវត្តតាមរយៈវិធានការជាកញ្ចប់ និងគ្រប់ជ្រុងជ្រោយដោយគ្របដណ្តប់មុំ ៤ គឺ ១)ការអភិវឌ្ឍទីផ្សារការងារ; ២)ការលើកស្ទួយសហគ្រាសធុនតូច និងមធ្យម និងសហគ្រិនភាព; ៣)ការរៀបចំ និងអនុវត្តភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន និង ៤) ការពង្រឹងការប្រកួតប្រជែង (ទំ. ៦៥) ។ | | |
| **ការអភិវឌ្ឍវិស័យឯកជន*** <br> កិច្ចសម្រួលពាណិជ្ជកម្ម ត្រូវបន្តពង្រឹងតាមរយៈការបញ្ចប់នូវការរៀបចំប្រព័ន្ធបញ្ជរជាតិតែមួយ, ការកែលម្អយន្តការត្រួតពិនិត្យនៅតាមព្រំដែនឱ្យស្ថិតក្នុងកម្រិតអប្បបរមា និងការបន្តកាត់បន្ថយនីតិវិធីទាក់ទង និងពាណិជ្ជកម្ម | ១. កែលម្អប្រព័ន្ធបញ្ជរជាតិតែមួយដែលជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាឱ្យកាន់តែមានប្រសិទ្ធភាព និងសាមញ្ញកម្ម | ១. ចំនួនសំណើសុំនាំចូលដោយពន្ធនាំចូលជាបន្ទុករបស់រដ្ឋតាមប្រព័ន្ធអនឡាញ មានការកើនឡើង |
| បរិយាកាសអំណោយផលសម្រាប់ធុរកិច្ច ការវិនិយោគ និងការអភិវឌ្ឍ ដែលកើតចេញពីកំណែទម្រង់ច្បាប់, ការធ្វើឱ្យប្រសើរឡើងនូវក្របខណ្ឌការលើកទឹកចិត្តវិនិយោគ និងភាពប្រសើរឡើងនៃភាពប្រកួតប្រជែង | ១. ចំនួនអ្នកវិនិយោគមកក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា កើនឡើង | ១.១. ចំនួនអ្នកវិនិយោគមកក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា កើនឡើង ១០% |
| | ២. ចំនួនទុនវិនិយោគ និងគម្រោងដែលចុះបញ្ជីនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា កើនឡើង | ២.១. ចំនួនទុនវិនិយោគដែលចុះបញ្ជីនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា កើនឡើង ២០% <br> ២.២. ចំនួនគម្រោងដែលចុះបញ្ជីនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា កើនឡើង ១០% |
| | ៣. ចំនួនការងារកើនឡើងបន្ថែម | ៣.១. ចំនួនការងារកើនឡើងបន្ថែម ៥% |

* សូចនាករតាមដានត្រូវបានកំណត់ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សម្រាប់អនុវត្ត និងតាមដានវឌ្ឍនភាព

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) |
|---|---|---|
| **ចតុកោណទី ៤ : ការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាប័ន្ន** -រាជរដ្ឋាភិបាលផ្តោតការយកចិត្តទុកដាក់ខ្ពស់លើការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាប័ន្ន ជាពិសេសផ្សារភ្ជាប់ទៅនឹង "**គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា**" ដែលតម្រូវឱ្យរាជរដ្ឋាភិបាលផ្តោតការយកចិត្តទុកដាក់លើ ១) ការលើកស្ទួយវិស័យកសិកម្ម និងការអភិវឌ្ឍជនបទ; ២) ការគ្រប់គ្រងធនធានធម្មជាតិ និងវប្បធម៌ ប្រកបដោយចីរភាព; ៣)ការពង្រឹងការគ្រប់គ្រងនគរូបនីយកម្ម និង ៤) ការធានាចីរភាពបរិស្ថាន និងការរៀបចំខ្លួនឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ (ទំ. ៧៥)។ | | |
| **វិស័យកសិកម្ម និងទឹក**<br><br>ជំរុញការអភិវឌ្ឍវិស័យកសិកម្មអោយមានសមត្ថភាពប្រកួតប្រជែង គុណភាព គុណតម្លៃអាហារូបត្ថម្ភ និងសុវត្ថិភាពផលិតផល ដោយផ្តោតការយកចិត្តទុកដាក់លើការពង្រឹងប្រសិទ្ធិផលក្នុងការគ្រប់គ្រងធនធានព្រៃឈើ និងជលផលប្រកបដោយនិរន្តភាព ការអភិវឌ្ឍ និងអភិរក្សធនធានទឹកប្រកបដោយ | ១. បង្កើនផលិតភាព និងពិពិធកម្មកសិកម្ម និងជំរុញបរិមាណនៃការនាំចេញ | ១.១. ផលិតភាពដីកសិកម្ម (បន្ទាត់មូលដ្ឋាន ២០២០: ១.៨០៤ ដុល្លារ/ហ.ត; ចំណុចដៅ ២០២៣: ២.០២៤ ដុល្លារ/ហ.ត)<br>១.២. ផលិតភាពកំលាំងពលកម្មក្នុងវិស័យកសិកម្ម (បន្ទាត់មូលដ្ឋាន ២០២០: ២.០០០ ដុល្លារ/កសិករ; ចំណុចដៅ ២០២៣: ២.៤១៦ ដុល្លារ/កសិករ)<br>១.៣. បង្កើនសមាមាត្រនៃពិពិធកម្មដំណាំ (បន្ទាត់មូលដ្ឋាន ២០២០: ៦៤,៥៥%; ចំណុចដៅ ២០២៣:៦៧,៧៩)<br>១.៤. បង្កើនបរិមាណនាំចេញនៃផលិតផលដំណាំសរុប (បន្ទាត់មូលដ្ឋាន ២០២០: ៦,២៩ លានតោន; ចំណុចដៅ ២០២៣: ៧,៧ លានតោន) |
| | ២. លើកកម្ពស់ផលិតកម្មសត្វ និងសុខភាពសត្វ | ២.១. បង្កើនផលិតកម្មសាច់សត្វសរុប (បន្ទាត់មូលដ្ឋាន ២០២០: ២៤៧ ពាន់តោន; ចំណុចដៅ ២០២៣: ២៧០ ពាន់តោន) |

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) |
| --- | --- | --- |
| ប្រសិទ្ធភាព សមធម៌ និងចីរភាព ដើម្បីរក្សាស្ថេរភាពប្រព័ន្ធអេកូឡូស៊ី និងកាត់បន្ថយគ្រោះធម្មជាតិនានា រួមមានគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត ដែលបានប៉ះពាល់ដល់សកម្មភាពប្រកបរបរចិញ្ចឹមជីវិត និងទ្រព្យសម្បត្តិសាធារណៈ | ៣. ធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងធនធានទឹក (ការគ្រប់គ្រង ថែទាំ និងការបង្កើតសហគមន៍កសិករប្រើប្រាស់ទឹក) ព្រមទាំងអភិវឌ្ឍ និងពង្រីកប្រព័ន្ធធារាសាស្ត្រ | ៣.១. អភិវឌ្ឍសមត្ថភាពធារាសាស្ត្រសម្រាប់ដំណាំស្រូវអោយបាន ៣០.០០០ ហ.ត/ឆ្នាំ (បន្ទាត់មូលដ្ឋាន ២០២១: ១.៨៩២.៣៥៩ ហ.ត; ចំណុចដៅ ២០២៣: ១.៩៥២.៣៥៩ ហ.ត)<br>៣.២. បង្កើនសមត្ថភាពស្រោចស្រពសម្រាប់ដំណាំរួមផ្សំនានា អោយបានដល់ ៥០០ ហ.ត/ឆ្នាំ (បន្ទាត់មូលដ្ឋាន ២០២១: ៤.៩១៣ ហ.ត; ចំណុចដៅ ២០២៣: ៦.៩១៣ ហ.ត)<br>៣.៣. បង្កើតសហគមន៍កសិករប្រើប្រាស់ទឹកចំនួន០៧/ឆ្នាំ (បន្ទាត់មូលដ្ឋាន ២០២១: ៥៦៥; ចំណុចដៅ ២០២៣: ៥៧៩)<br>៣.៤. បង្កើនការប្រតិបត្តិ និងថែទាំប្រព័ន្ធធារាសាស្ត្រទាំង៤១ ប្រព័ន្ធ/ឆ្នាំ (បន្ទាត់មូលដ្ឋាន ២០២១: ៣៣១; ចំណុចដៅ ២០២៣: ៤១៣)<br>៣.៥. បង្កើនការកសាងសមត្ថភាពសហគមន៍កសិករប្រើប្រាស់ទឹកអោយបាន ១៥/ឆ្នាំ (បន្ទាត់មូលដ្ឋាន ២០២១: ១៤៨; ចំណុចដៅ ២០២៣: ១៧៨) |

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) |
|---|---|---|
| **ការកែទម្រង់ព្រៃឈើ**<br><br>ត្រូវបានបង្កើន និងធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងប្រកបដោយនិរន្តរភាព រួមមាន ធនធានព្រៃផ្តល់ផលសហគមន៍ព្រៃឈើ និងសត្វព្រៃ ពង្រឹងការអនុវត្តច្បាប់, ការដាំព្រៃឈើឡើងវិញ, ការស្តារតំបន់ទេសភាពព្រៃឈើ, ការស្រាវជ្រាវ និងការអភិវឌ្ឍព្រៃឈើ និងសត្វព្រៃ និងការបង្កើនជីវភាពសហគមន៍ព្រៃឈើ | ១. ការគ្រប់គ្រងព្រៃផ្តល់ផល និងសហគមន៍ព្រៃឈើបានប្រសើរឡើង | ១.១. គោលការណ៍ណែនាំស្តីពីដំណើរការរៀបចំផែនការគ្រប់គ្រងព្រៃសហគមន៍ ត្រូវបានកែសម្រួល (បន្ទាត់មូលដ្ឋាន: 0; ចំណុចដៅ: គោលការណ៍ណែនាំត្រូវបានអនុម័ត)<br>១.២. ចំនួនផែនការគ្រប់គ្រងសហគមន៍ព្រៃឈើ (២០ សហគមន៍ព្រៃឈើ/ឆ្នាំ) ត្រូវបានអនុម័ត (បន្ទាត់មូលដ្ឋាន ២០២០: ១០៣ សហគមន៍ព្រៃឈើ [៧០.៩៩១ ហ.ត] ; ចំណុចដៅ: ៦០ សហគមន៍ព្រៃឈើ)<br>១.៣. ចំនួនសហគមន៍ព្រៃឈើទទួលបានហិរញ្ញប្បទានសម្រាប់គម្រោងបង្កើនជីវភាព (បន្ទាត់មូលដ្ឋាន ២០២០: ៥៤ សហគមន៍ព្រៃឈើ; ចំណុចដៅ: ៣០ សហគមន៍ព្រៃឈើ)<br>១.៤. ទំហំផ្ទៃដីព្រៃឈើរេចរឹលត្រូវបានដាំដើមឈើឡើងវិញ (បន្ទាត់មូលដ្ឋាន ២០២០: ៤.២៥០,១៨ ហ.ត; ចំណុចដៅ: ១៥.០០០ ហ.ត)<br>១.៥. ចំនួនកូនឈើបានបណ្តុះ និងចែកជូនសាធារណជន និងសហគមន៍មូលដ្ឋាន (បន្ទាត់មូលដ្ឋាន ២០២០: ៤.៦០៥.៩១១ដើម; ចំណុចដៅ: ១.៨០០.០០០ ដើម) |
| | ២. ធនធានជីវចម្រុះត្រូវបានការពារ និងគុណភាពកើនឡើង | ២.១. ចំនួនសត្វព្រៃត្រូវបានសង្គ្រោះ និងដោះលែង (បន្ទាត់មូលដ្ឋាន ២០២០: ៤.១៥៥សត្វ; ចំណុចដៅ: ២.៤០០សត្វ)<br>២.២. ឡូត៍ពិសោធន៍ដាំពូជឈើត្រូវបានបង្កើត (បន្ទាត់មូលដ្ឋាន ២០២០: ៧១.៥០ហ.ត; ចំណុចដៅ: ៣០ ហ.ត) |

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) |
|---|---|---|
| | ៣. ការអនុវត្តច្បាប់ព្រៃឈើ និង អភិបាលកិច្ចកាន់តែមានប្រសិទ្ធភាព | ៣.១. ចំនួនអ្នកពាក់ព័ន្ធបានទទួលការបណ្តុះបណ្តាល និងចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ (បន្ទាត់មូលដ្ឋាន ២០២០: ១៤៦៣ នាក់ [ស្ត្រី ៥៦៦ នាក់]; ចំណុចដៅ: ៦០០នាក់)<br>៣.២. ការរៀបចំកំណត់និយមន័យឈើស្របច្បាប់សម្រាប់ប្រទេសកម្ពុជា (បន្ទាត់មូលដ្ឋាន: 0; ចំណុចដៅ: និយមន័យឈើស្របច្បាប់ត្រូវបានកំណត់)<br>៣.៣. បង្កើតប្រព័ន្ធគ្រប់គ្រងព័ត៌មានធនធានព្រៃឈើ (Forest Resource Management Information System) (បន្ទាត់មូលដ្ឋាន: 0; ចំណុចដៅ: ប្រព័ន្ធគ្រប់គ្រងព័ត៌មានធនធានព្រៃឈើត្រូវបានបង្កើត) |
| | ៤. យុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ការគ្រប់គ្រងព្រៃផ្តល់ផល និងព្រៃសហគមន៍ ត្រូវបានរៀបចំ | ៤.១. ការអភិវឌ្ឍន៍ផែនការយុទ្ធសាស្ត្រព្រៃផ្តល់ផល (Production Forest Strategic Plan) ២០២១-២០៣០ (បន្ទាត់មូលដ្ឋាន: 0; ចំណុចដៅ: ផែនការយុទ្ធសាស្ត្រព្រៃផ្តល់ផលត្រូវបានអនុម័ត និងចាប់ផ្តើមដំណើរការ)<br>៤.២. ការអភិវឌ្ឍន៍ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពស្តីពី ការបញ្ជ្រាបយេនឌ័រក្នុងវិស័យព្រៃឈើ ២០២១-២០២៥ (បន្ទាត់មូលដ្ឋាន: 0; ចំណុចដៅ: ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាព ស្តីពីការបញ្ជ្រាបយេនឌ័រក្នុងវិស័យព្រៃឈើត្រូវបានអនុម័ត និងចាប់ផ្តើមដំណើរការ) |

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) |
| --- | --- | --- |
| **ការកែទម្រង់ជលផល**<br><br>ពង្រឹងការគ្រប់គ្រង និងអភិវឌ្ឍធនធានជលផលប្រកបដោយនិរន្តរភាព | ១. រក្សាបាននូវផលនេសាទពីធម្មជាតិ | ១.១. ផលនេសាទបានពីគ្រប់ប្រភពរក្សាបានក្នុងបរិមាណ ៦០០.០០០ តោន ក្នុងមួយឆ្នាំ រួមទាំងផលនេសាទសមុទ្រប្រមាណ ១០០.០០០តោន [ចំណុចដៅក្របខណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផល] (បន្ទាត់មូលដ្ឋាន ២០២០: ៥៣៥.៩០០ តោន រួមបញ្ចូល ១២២.៧០០ តោន ពីផលនេសាទសមុទ្រ; ចំណុចដៅ ២០២៣: ៦០០.០០០ តោន)<br>១.២. តំបន់អភិរក្សជលផលរបស់រដ្ឋ ត្រូវបានគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព [ផ្តល់ពិន្ទុធំជាង ៤ ដោយប្រើវិធីសាស្ត្រវាយតម្លៃរបស់នាយកដ្ឋានអភិរក្សជលផល] (បន្ទាត់មូលដ្ឋាន ២០១៨: តំបន់អភិរក្សទឹកសាប ៦៦.១២០ ហ.ត និងតំបន់អភិរក្សសមុទ្រ ២.៤៦៩ ហ.ត ត្រូវបានវាយតម្លៃថាបានការពារប្រកបដោយប្រសិទ្ធភាព; ចំណុចដៅ២០២៣: តំបន់អភិរក្សទឹកសាប ១៧២.៧៤៦ ហ.ត និងតំបន់អភិរក្សសមុទ្រ ៩.៨៤០ ហ.ត)<br>១.៣. ចំនួនសហគមន៍នេសាទ និងសហគមន៍ចិញ្ចឹមត្រី ដំណើរការល្អ [ការដាក់ពិន្ទុធំជាង ៤ សហគមន៍នេសាទ/ សហគមន៍ចិញ្ចឹមត្រី។ វាយតម្លៃប្រសិទ្ធភាព អនុវត្តដោយនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍នេសាទ CFDD និង DAD] (បន្ទាត់មូលដ្ឋាន ២០១៨: សហគមន៍នេសាទ៥០ និងចំនួនស្នាទសហគមន៍ចិញ្ចឹមត្រី ៥០; ចំណុចដៅ២០២៣: សហគមន៍នេសាទចំនួន ៣០០ និងសហគមន៍ចិញ្ចឹមត្រីចំនួន ៣២៥) |
| | ២. ផលិតផលវារីវប្បកម្មកើនឡើង ២០% ក្នុងមួយឆ្នាំ | ២.១. ទិន្នផលវារីវប្បកម្មសរុបទាំង ទឹកសាប និងសមុទ្រ (បន្ទាត់មូលដ្ឋាន ២០២០: ៤០០.៤០០ តោន; ចំណុចដៅ ២០២៣: ៦១៩.០០០ តោន)<br>២.២. បង្កើនចំនួនកសិករបណ្តុះបណ្តាលពីវារីវប្បកម្ម GAqP (បន្ទាត់មូលដ្ឋាន: គ្មាន; ចំណុចដៅ ២០២៣: ៣.០០០) |

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) |
|---|---|---|
| | | ២.៣. បង្កើនចំនួនស្ថានីយ៍ផលិតកូនត្រីពូជពីវារីវប្បកម្ម (បន្ទាត់មូលដ្ឋាន: គ្មាន; ចំណុចដៅ ២០២៣: ១០០)<br>២.៤. ផលិតកម្មកូនត្រីពីស្ថានីយ៍ផលិតកូនត្រី (រដ្ឋ និងឯកជន) (បន្ទាត់មូលដ្ឋាន ២០២០: ២៣៥លានកូនត្រី; ចំណុចដៅ ២០២៣: ៣៥០លានកូនត្រី) |
| | ៣. លើកកម្ពស់គុណភាព និងសុវត្ថិភាពផល និងផលិតផលជលផល ដែលបានពីវារីវប្បកម្មនិងធម្មជាតិ | ៣.១. ចំនួនការត្រួតពិនិត្យប្រចាំឆ្នាំនៃ ទីតាំងជលផល (រួមទាំងកសិដ្ឋានចិញ្ចឹមត្រី) សម្រាប់ផលិតផលនេសាទ (បន្ទាត់មូលដ្ឋាន ២០២០: ៥០; ចំណុចដៅ ២០២៣: ២០០)<br>៣.២. ចំនួនទីតាំងថែរក្សាត្រី និងកែច្នៃ (រួមទាំងកសិដ្ឋានចិញ្ចឹមត្រី) ត្រូវបានបញ្ជាក់ថាការអនុវត្តអនាម័យល្អ (បន្ទាត់មូលដ្ឋាន: គ្មាន; ចំណុចដៅ ២០២៣: ១០០) |
| **វិស័យមីន**<br><br>កម្មវិធីសកម្មភាពមីនជាតិ ឆ្លើយតបទៅនឹងបញ្ហាសន្តិសុខមនុស្សជាតិ និងគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម | ១. ដីដែលដឹងថាមានមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម (ស.ផ.ស.) បានបោសសម្អាតរួច ដើម្បីគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម | ១.១. រំដោះផ្ទៃដីសង្ស័យមានមីន / សំណល់ជាតិផ្ទុះពីសង្គ្រាមឱ្យបាន ២១.៤០០ ហ.ត/១ឆ្នាំ<br>១.២. ផ្ទៃដីដែលបានសម្អាតមីន និងគ្រាប់បែកចង្កោមរួចទាំងអស់ ត្រូវបានប្រើប្រាស់សម្រាប់គាំទ្រការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម |
| | ២. កាត់បន្ថយចំនួនជនរងគ្រោះដោយសារមីន / ស.ផ.ស. | ២.១. ចំនួនជនរងគ្រោះដោយសារមីន / ស.ផ.ស. ត្រូវបានថយចុះ ១០% ក្នុងមួយឆ្នាំ |

| លទ្ធផលចុងក្រោយ (២០១៩-២០២៣) | លទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) | សូចនាករលទ្ធផលក្នុងឆ្នាំ (២០២១-២០២៣) |
|---|---|---|
| | ៣. ជនរងគ្រោះដោយសារមីន/ ស.ផ.ស បានយល់ដឹងពីសិទ្ធិ និងទទួលបានការថែទាំផ្នែកវេជ្ជសាស្ត្រ និងផ្លូវចិត្ត និងសេវាកម្មស្តារលទ្ធភាពពលកម្មកាយសម្បទា ព្រមទាំងលើកកម្ពស់ការស្វែងរកការគាំទ្រមតិសម្រាប់ជនពិការនៅក្នុងវេទិកាជាតិនិងអន្តរជាតិ | ៣.១. ជនរងគ្រោះដោយសារមីន / ស.ផ.ស. ចំនួន ១.០០០នាក់ បានយល់ដឹងពីសិទ្ធិរបស់ពួកគេ និងការថែទាំផ្នែកវេជ្ជសាស្ត្រ និងផ្លូវចិត្ត និងសេវាកម្មស្តារលទ្ធភាពពលកម្មកាយសម្បទា<br>៣.២. ជនរងគ្រោះដោយសារមីន / ស.ផ.ស. ចំនួន ៣.០០០នាក់ បានទទួលការថែទាំផ្នែកវេជ្ជសាស្ត្រ និងផ្លូវចិត្ត និងសេវាកម្មស្តារលទ្ធភាពពលកម្មកាយសម្បទា<br>៣.៣. ការចូលរួមយ៉ាងសកម្មរបស់អាជ្ញាធរមីនក្នុងវេទិកាកិច្ចប្រជុំជាតិ និងអន្តរជាតិ ដើម្បីកិច្ចការងារគាំទ្រ និងលើកស្ទួយជនរងគ្រោះដោយសារមីន / ស.ផ.ស. |
| **ការប្រែប្រួលអាកាសធាតុ***<br><br>កម្រិតត្រៀមរបស់ស្ថាប័នក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ (CSDG គោលដៅ ១៣ និង NSDP)-ផ្នែកព័ត៌មាន | ១. យុទ្ធសាស្ត្ររយៈពេលវែងសម្រាប់អព្យាក្រឹតកាបូន (Carbon Neutrality) | ១.១. ស្ថានភាពនៃយុទ្ធសាស្ត្ររយៈពេលវែងសម្រាប់អព្យាក្រឹតកាបូន (បន្ទាត់មូលដ្ឋាន: គ្មាន; ចំណុចដៅ: យុទ្ធសាស្ត្រត្រូវបានរៀបចំ និងសម្រេចដាក់ជាផ្លូវការទៅកាន់លេខាធិការដ្ឋាន UNFCCC) |
| | ២. យន្តការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ | ២.១. ស្ថានភាពនៃអនុក្រឹត្យស្តីពីយន្តការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ (បន្ទាត់មូលដ្ឋាន: សេចក្តីព្រាង; ចំណុចដៅ: អនុក្រឹត្យត្រូវបានអនុម័ត) |
| | ៣. ប្រព័ន្ធតាមដាន រាយការណ៍ និងផ្ទៀងផ្ទាត់ (MRV) សម្រាប់ការប្តេជ្ញារបស់ខ្លួន ក្រោម NDC ត្រូវបានដាក់ឱ្យដំណើរការ | ៣.១. ស្ថានភាពនៃប្រព័ន្ធតាមដាន ការរាយការណ៍ និងការផ្ទៀងផ្ទាត់ MRV សម្រាប់ NDCកម្ពុជា ត្រូវបានរៀបចំឡើង (បន្ទាត់មូលដ្ឋាន ២០១៨: មិនទាន់ដំណើរការ; ចំណុចដៅ ២០២១: បានដំណើរការ) |

* សូចនាករតាមដានត្រូវបានកំណត់ដោយក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព នៃក្រសួងបរិស្ថាន សម្រាប់ការអនុវត្ត និងតាមដានវឌ្ឍនភាព